## នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

### ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ជ

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្តី នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Jun-2013, 09:50
CMS/CFO: Sann Rada

### ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ : សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## បណ្តឹងសាទុក្ខតាមៗជំទាស់នឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសារណាតបចំពោះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាជំទាស់នឹងសេចក្តីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី នួន ជា:**

សុន អារុណ

Victor KOPPE

ព្រុំ ផល្លា

សួន វិសាល

**ចម្លងជូន:**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា:**

ជា លាង

Andrew CAYLEY

Joshua ROSENSWEIG
Forest O'NEILL-GREENBERG

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Elisabeth SIMONNEAU FORT

អនុលោមតាមវិធាន ១០៤(១), ១០៤(៤) និង ១០៥(២) នៃវិធានផ្ទៃក្នុង អ.វ.ត.ក ("វិធាន") សហមេធាវីការពារក្តី នួន ជា ("មេធាវីការពារក្តី") សូមដាក់បណ្តឹងសាទុក្ខភ្លាមៗជំទាស់នឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ("សេចក្តីសម្រេចដែលត្រូវបានជំទាស់")[1] និងសារណាតបទៅលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ("បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី")[2] ជំទាស់នឹងសេចក្តីសម្រេចដដែលនោះ៖

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញដីកាបង្គាប់ឲ្យបំបែកកិច្ចដំណើរការនីតិវិធីនៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ទៅជាសវនាការតូចៗដែលមិនមានចំនួនច្បាស់លាស់ និងបានចង្អុលបង្ហាញថា សវនាការក្នុងវគ្គទី ១ ដែលមានឈ្មោះថា សំណុំរឿង ០០២/០១ នឹងផ្តោតទៅលើការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី១ និង ទី២ ("ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីទី១")[3]។ សហព្រះរាជអាជ្ញាស្នើសុំឲ្យពិចារណាសាជាថ្មីចំពោះសេចក្តីសម្រេចនេះ ដោយស្នើឲ្យពង្រីកសំណុំរឿង ០០២/០១ ដោយបញ្ចូលបទចោទផ្សេងៗឲ្យច្រើនជាងនេះក្នុងសំណុំរឿង ០០២[4]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើនោះ[5]។

---

1 ឯកសារលេខ **E284**, "សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣", ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ("សេចក្តីសម្រេចដែលត្រូវបានជំទាស់")។

2 ឯកសារលេខ **E284/2/1**, "បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២", ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ ("បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី")។

3 ឯកសារលេខ **E124**, "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង", ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីទី១"។

4 ឯកសារលេខ **E124/2**, ""សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញទៅលើ "ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង", ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១។

2. នៅថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានស្នើសុំជាថ្មីម្តងទៀតឲ្យកែប្រែវិសាលភាពសំណុំរឿង ០០២/០១ ដោយបញ្ចូលការចោទប្រកាន់ផ្សេងៗពាក់ព័ន្ធនឹងមន្ទីរ ស២១ និងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ និងនៅស្រុក ១២ [6]។ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកសំណើនោះមួយផ្នែក ដោយបន្ថែមទួលពោធិ៍ជ្រៃទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ តែបដិសេធមិនទទួលយកសំណើពាក់ព័ន្ធនឹងមន្ទីរ ស២១ និង ស្រុក១២[7]។ សហព្រះរាជអាជ្ញាបានប្តឹងសាទុក្ខជំទាស់នឹងសេចក្តីសម្រេចនោះ ("បណ្តឹងសាទុក្ខលើកទី១ ជំទាស់នឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី")[8]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចលើបណ្តឹងសាទុក្ខថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងជាច្រើនករណី និងបានមោឃៈដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីទី ១ និងសេចក្តីសម្រេចពីរទៀតរបស់អង្គជំនុំជម្រះសាលាដំបូង ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើការបំបែកកិច្ចដំណើរការនីតិវិធី")[9]។

3. អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការនៅសប្តាហ៍ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ក្នុងគោលបំណងដើម្បីប្រមូលយកសេចក្តីសន្និដ្ឋាននានាពីភាគីពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ ("សវនាការលើការបំបែកកិច្ចដំណើរការនីតិវិធី")។ នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានប្រកាសពីសេចក្តីសម្រេចរបស់ខ្លួន ដើម្បីបំបែកសំណុំរឿង ០០២ ម្តងទៀត និងដើម្បី

---

5 ឯកសារលេខ E124/7, "សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ", ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើសំណើសុំការពិចារណាឡើងវិញ")។

6 ឯកសារលេខ E163, "សំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១", ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២។

7 ឯកសារលេខ E163/5, អនុស្សរណៈពីប្រធានអង្គជំនុំជម្រះសាលាដំបូង, ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២។

8 ឯកសារលេខ E163/5/1/1, "បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹង "សេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿង ០០២/០១ មានឧបសម្ព័ន្ធ (I) និង ឧបសម្ព័ន្ធសម្ងាត់ (II)"", ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០១២ ("បណ្តឹងសាទុក្ខលើកទី១ ជំទាស់នឹងសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី")។

9 ឯកសារលេខ E163/5/1/13, ("សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០១", ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើការបំបែកកិច្ចដំណើរការនីតិវិធី")។

ដំណើរការសវនាការក្នុងសំណុំរឿង ០០២/០១ ដែលមានវិសាលភាពដូចគ្នាបេះបិទទៅនឹងសេចក្ដីសម្រេចកាលពី ខែ តុលា ឆ្នាំ ២០១២[10]។ នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានដាក់សំអាងហេតុរបស់ខ្លួនសម្រាប់សេចក្ដីសម្រេចនោះ (“សេចក្ដីសម្រេចដែលត្រូវបានជំទាស់”)។ នៅថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានដាក់បណ្ដឹងសាទុក្ខលើកទី២ ជំទាស់នឹងសេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី។

## II. សេចក្ដីសម្រេចដែលត្រូវបានជំទាស់

4. ក្នុងការបដិសេធដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីទី១ អង្គជំនុំជម្រះតុលាការកំពូលបានគាំទ្រអំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធី និងភាពពាក់ព័ន្ធនៃការពិចារណាសំខាន់ៗ ដែលអង្គជំនុំជម្រះសាលាដំបូងយកមកសំអាងដើម្បីចេញសេចក្ដីសម្រេចរបស់ខ្លួន[11]។ ថ្វីត្បិតតែយ៉ាងណានេះក្ដី អង្គជំនុំជម្រះតុលាការកំពូលបានសន្និដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ដោយមិនបានពិគ្រោះយោបល់ជាមួយភាគី[12] មិនបានបង្ហាញសំអាងហេតុពេញលេញសម្រាប់សេចក្ដីសន្និដ្ឋានរបស់ខ្លួន[13] មិនបានផ្ដល់ការពិចារណាដល់ភាពជាតំណាងនៃសំណុំរឿង ០០២/០១ ពាក់ព័ន្ធនឹងសំណុំរឿង ០០២ ទាំងមូល[14] និងមិនបានបង្ហាញអំពីផែនការសម្រាប់សវនាការនាពេលអនាគត[15]។

5. សេចក្ដីសម្រេចលើកទី២ របស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី (សេចក្ដីសម្រេចដែលត្រូវបានជំទាស់) បានដោះស្រាយចំណុចទាំងនេះមួយផ្នែក។ អង្គជំនុំជម្រះសាលាដំបូងបានប្រមូលយកសេចក្ដីសន្និដ្ឋាននានាពីភាគី និងផ្ដល់សំអាងហេតុពិស្ដារសម្រាប់សេចក្ដីសម្រេចរបស់ខ្លួន។

---

10 ឯកសារលេខ **E1/176.1**, “ប្រតិចារឹកនៃកិច្ចដំណើរការសវនាការ”, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣, ទំព័រ ៤:១៣-១៧ (ភាសាអង់គ្លេស)។

11 សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៣៦, ៤៩។

12 សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៤០។

13 សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៤១។

14 សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៤២។

15 សេចក្ដីសម្រេចរបស់ អ.ជ.ត.ក លើការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ២៤, ៤៦ ដល់ ៤៧។

អង្គជំនុំជម្រះសាលាដំបូងក៏បានធ្វើការពិចារណាអំពីភាពជាតំណាងនៅក្នុងសំណុំរឿង ០០២/០១ និងអំពីការបញ្ចូលមន្ទីរ ស២១ ទៅក្នុងវិសាលភាព។ ក្នុងន័យនោះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា អាចថាមិនអាចបញ្ចប់សវនាការដែលមានភាពជាតំណាងគ្រប់គ្រាន់បើមើលទៅលើអាយុកាលរបស់ជនជាប់ចោទនោះ[16] ហើយថា ក្នុងកាលៈទេសៈទាំងនោះ ជាការសមរម្យដែលត្រូវផ្តោតទៅលើដំណាក់កាលនៃអង្គហេតុដែលពាក់ព័ន្ធនឹងប្រជាជនកម្ពុជាជាច្រើនបំផុតវិញ[17]។ បើតាមការប៉ាន់ស្មានរបស់អង្គជំនុំជម្រះសាលាដំបូង ការជម្លៀសដោយបង្ខំបានឆ្លើយតបទៅនឹងលក្ខណវិនិច្ឆ័យនោះជាងគេ[18]។ ការចោទប្រកាន់ផ្សេងទៀតនៅក្នុងដីកាដំណោះស្រាយ រួមទាំង មន្ទីរ ស២១ និងបទចោទពីអំពើប្រល័យពូជសាសន៍ ដែលពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មនីមួយៗ និង/ឬ មានវិសាលភាពតូចមួយក្នុងចំណោមជនរងគ្រោះទាំងមូល[19]។ ដោយពុំមានមូលដ្ឋានជាគោលការណ៍ដើម្បីបែងចែករវាងចំណុចដែលអាចនឹងបញ្ចូលក្នុងសំណុំរឿង ០០២/០១ នោះ អង្គជំនុំជម្រះតុលាការកំពូលបានជ្រើសរើសបញ្ចូលតែការចោទប្រកាន់បន្ថែមទៀត ដែលមានទំនាក់ទំនងសមស្របជាមួយនឹងការជម្លៀសដោយបង្ខំតែប៉ុណ្ណោះ[20]។

6. អង្គជំនុំជម្រះសាលាដំបូងក៏រៀបចំផែនការមួយសម្រាប់សវនាការនាពេលអនាគតដែរ។ ផែនការនោះបានកំណត់អំពីការចោទប្រកាន់នានាក្នុងដីកាដំណោះស្រាយ ដែលនឹងត្រូវជំនុំជម្រះក្នុងសវនាការពីរបន្តបន្ទាប់ទៀត។ ដោយលើកពីការកើតឡើងដោយយថាហេតុ អង្គជំនុំជម្រះសាលាដំបូងពុំបានផ្តល់ពេលវេលាកំណត់ ពាក់ព័ន្ធនឹងសវនាការទាំងនោះទេ ទោះបីអង្គជំនុំជម្រះពិតជាបានលើកឡើងថា សំណុំរឿង ០០២/០២ នឹងចាប់ផ្តើមក្នុងពេលឆាប់ៗបន្ទាប់ពី "បញ្ចប់" សំណុំរឿង ០០២/០១ ក៏ដោយ។ អង្គជំនុំជម្រះក៏មិនបានឆ្លើយតបទៅនឹងឧបសគ្គនានាទាំងផ្នែកច្បាប់ និងទាំងការអនុវត្តន៍ដែលកើតមានចំពោះសវនាការបន្តបន្ទាប់នៅ អ.វ.ត.ក ដែលភាគី និងអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងទេ[21]។

## III. ឧទ្ធរណ៍

[16] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១០៩។

[17] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១១០។

[18] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១១០, ១១២, ១១៥។

[19] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១១២ ដល់ ១១៣។

[20] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១១៦។

[21] *សូមមើល* កថាខណ្ឌ ១២ ដល់ ២១, *ខាងក្រោម*, សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១៥០ ដល់ ១៥៥។

## A. បណ្ដឹងសាទុក្ខនេះ និងសារណាតបអាចទទួលយកបាន

7. កាលបរិច្ឆេទកំណត់រយៈពេល ៣០ ថ្ងៃសម្រាប់ប្ដឹងសាទុក្ខជំទាស់នឹងសេចក្ដីសម្រេចដែលត្រូវបានជំទាស់ ដែលត្រូវបានចេញនៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ផុតកំណត់នៅថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣[22]។ កាលបរិច្ឆេទកំណត់រយៈពេល ១០ ថ្ងៃសម្រាប់ឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខលើកទី២ របស់សហព្រះរាជអាជ្ញា ជំទាស់នឹងសេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដែលត្រូវបានជូនដំណឹងនៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៣ នឹងផុតកំណត់នៅថ្ងៃដដែលនោះដែរ[23]។ ហេតុនេះ បណ្ដឹងសាទុក្ខ និងសារណាតប សុទ្ធតែត្រូវបានដាក់ទាន់ពេលវេលា។

8. មេធាវីការពារក្ដីយល់ស្របជាមួយសហព្រះរាជអាជ្ញា ទោះបីមានសំអាងហេតុខុសៗគ្នាបន្តិចបន្តួចក៏ដោយថា បណ្ដឹងសាទុក្ខជំទាស់នឹងសេចក្ដីសម្រេចដែលត្រូវបានជំទាស់ អាចទទួលយកបាន អនុលោមតាមវិធាន ១០៤(៤)(ក) និង ១០៤(១)[24]។ ទោះបីមេធាវីការពារក្ដីពុំមានមូលដ្ឋានឯករាជ្យដែលអាចសន្និដ្ឋានថា សវនាការក្នុងសំណុំរឿង ០០២/០២ "ជាក់ស្ដែងនៅឆ្ងាយ" ក៏ដោយ[25] ក៏អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចរួចមកហើយថា ប្រសិនបើមានការសង្ស័យកើតឡើងពាក់ព័ន្ធនឹងលទ្ធភាពនៃកិច្ចដំណើរការនីតិវិធីបន្ថែមទៀត បន្ទាប់ពីសំណុំរឿង ០០២/០១ នោះវាគ្រប់គ្រាន់អាចឲ្យអនុវត្តវិធាន ១០៤(៤)(ក) បានហើយ[26]។ មេធាវីការពារក្ដីកត់សម្គាល់បន្ថែមទៀតថា សេចក្ដីសម្រេចដែលត្រូវបានជំទាស់ សម្រេចមិនត្រឹមតែដកមន្ទីរ ស២១ ចេញពីកិច្ចដំណើរការនីតិវិធីដែលកំពុងដំណើរការប៉ុណ្ណោះទេ តែថែមទាំងដកចេញតុល្យភាពនៃដីកាដំណោះស្រាយទៀតផង។

## B. អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ក្នុងការសម្រេចបំបែកដីកាដំណោះស្រាយ

---

[22] វិធាន ១០៧(១)។

[23] សេចក្ដីណែនាំអនុវត្តន៍ស្ដីពីការដាក់ឯកសារ, សេចក្ដីណែនាំអនុវត្តន៍លេខ *អវតក/០១/២០០៧/វិ.៧,* មាត្រា ៨.៣។ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៣ គឺជាថ្ងៃឈប់សម្រាកនៅ អ.វ.ត.ក។

[24] បណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីរ ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ១៥ ដល់ ១៩។

[25] បណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីរ ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ១៩។ *សូមមើល* កថាខណ្ឌ ៣៤ ដល់ ៣៧ *ខាងក្រោម*។

[26] បណ្ដឹងសាទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីរ ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ២៥។

9. អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិវាយតម្លៃឡើងវិញទៅលើការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ បន្ទាប់ពីមោឃភាពដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីទី ១ តែក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចបានបុរេលក្ខខណ្ឌមួយចំនួនប៉ុណ្ណោះ[27]។ ទោះបីសេចក្តីសម្រេចដែលត្រូវបានជំទាស់បានដោះស្រាយចំណុចទាំងនោះមួយផ្នែកក៏ដោយ តែសេចក្តីសម្រេចនេះមិនបានឆ្លើយតបទៅតាមការណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូលត្រង់ពីរចំណុច៖ សេចក្តីសម្រេចនេះមិនបានពិចារណាទៅលើសេចក្តីសន្និដ្ឋាននានារបស់មេធាវីការពារក្តីពាក់ព័ន្ធនឹងការបំបែកដីកាដំណោះស្រាយ ហើយមិនបានបង្កើតជាផែនការមួយគ្រប់គ្រាន់ដើម្បីដោះស្រាយឧបសគ្គនានាផ្នែកច្បាប់ និងការអនុវត្ត នៅក្នុងការរៀបចំសវនាការជាបន្តបន្ទាប់នៅ អ.វ.ត.ក នោះទេ។ កំហុសឆ្គងទាំងនេះតម្រូវឲ្យមោឃភាពសេចក្តីសម្រេចដែលត្រូវបានជំទាស់នោះ។

10. ទោះបីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលផ្តោតជាសំខាន់ទៅលើទម្រង់នៃសំណុំរឿង ០០២/០១ ក៏ដោយ ក៏សេចក្តីសម្រេចបានបង្ហាញថា សេចក្តីសម្រេចដើម្បីបំបែកសវនាការ បណ្តាលឲ្យមាន "បញ្ហាជាបឋម" ដែរថា៖

> ការពិចារណាទៅលើប្រសិទ្ធភាព និងយុត្តិធម៌ តម្រូវឲ្យអនុវត្តតាមគោលការណ៍ជាទូទៅដែលមានចែងក្នុងច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក ក៏ដូចជា នៅក្នុងយុត្តាធិការនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលថា បទចោទពាក់ព័ន្ធនឹងព្រឹត្តិការណ៍ស្រដៀងគ្នាចំពោះជនជាប់ចោទជាច្រើនរូប គប្បីត្រូវជំនុំជម្រះនៅក្នុងកិច្ចដំណើរការនីតិវិធីបញ្ចូលគ្នា។ ការបំបែកដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលបានសម្រេចរួចហើយនោះ ពុំមានចែងនៅក្នុងច្បាប់កម្ពុជានោះឡើយ ហើយតុលាការព្រហ្មទណ្ឌអន្តរជាតិ*ពិសេស*មានការស្ទាក់ស្ទើរក្នុងការទទួលយកសំណើសុំបំបែកកិច្ចដំណើរការនីតិវិធីនេះ។ ការបំបែកនេះមានលក្ខណៈចាំបាច់ នៅពេលដែលការបំបែកនេះជាប់ពាក់ព័ន្ធទៅនឹងការបំបែកជនជាប់ចោទម្នាក់ចេញពីកិច្ចដំណើរការនីតិវិធីបញ្ចូលគ្នានោះ[28]។ (គូសបញ្ជាក់បន្ថែម)

[27] សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៥០។

[28] សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៣៣។

11. ការអនុវត្តជាអន្តរជាតិទទួលស្គាល់ថា អង្គហេតុទាំងឡាយដែលកើតចេញពីព្រឹត្តិការណ៍នានា ជាធម្មតាត្រូវបានស្តាប់ចម្លើយនៅក្នុងការជំនុំជម្រះក្តីរួមតែមួយ[29]។ ហេតុដូច្នេះ មុនពេលចេញដីកាបំបែកកិច្ចដំណើរការនីតិវិធីសម្រាប់បទចោទរួម តុលាការត្រូវបានស្នើសុំឱ្យធ្វើការពិចារណាលើ៖

> ១) ព្យសនកម្មដែលអាចមានទៅលើសិទ្ធិរបស់ជនជាប់ចោទ [...] ២) កត្តាផ្សេងៗទៀតដែលទាក់ទិនទៅនឹងផលប្រយោជន៍នៃយុត្តិធម៌ ជាពិសេស លទ្ធភាពដែលអាចគ្រប់គ្រងបានដែលពាក់ព័ន្ធសម្រាប់អង្គជំនុំជម្រះ និងភាគីនានានៃការជំនុំជម្រះក្តីរួមតែមួយដែលតទល់នឹងការជំនុំជម្រះក្តីដោយឡែក។ និង ៣) បន្ទុកដែលអាចមានលើសាក្សីនានា[30]។

កត្តាទាំងអស់នេះអាចអនុវត្តបាននៅក្នុងករណីនេះ ហើយគួរតែធ្វើឱ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចបើកការជំនុំជម្រះក្តីរួមតែមួយទៅលើដីកាដំណោះស្រាយសំណុំរឿង ០០២ ទាំងស្រុង។

i- <u>ការបំបែកកិច្ចដំណើរការនីតិវិធីមិនស្របទៅនឹងសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នោះទេ</u>

12. បទពិសោធន៍នៃសវនាការសំណុំរឿង ០០២/០១ បានបង្ហាញថា ការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយមានការពាក់ព័ន្ធគ្នាខ្លាំងពេក ដែលមិនអនុញ្ញាតឱ្យមានការបំបែកទៅជាការជំនុំជម្រះក្តីដាច់ដោយឡែកពីគ្នា។ កិច្ចប្រឹងប្រែងក្នុងការធ្វើដូច្នេះនៅក្នុងសំណុំរឿង ០០២/០១ បានបង្កឱ្យមានព្យសនកម្មទៅលើសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌ និងធ្វើឱ្យមិនអាចគ្រប់គ្រងសំណុំរឿង ០០២/០១ បានផងដែរ។ ការជំនុំជម្រះក្តីជាវគ្គៗនៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះតែមួយ នឹងកាន់តែរំលោភថែមទៀតទៅលើសច្ចធារណ៍នៃនិរទោស និងសិទ្ធិក្នុងការមានសាលាក្តីឯករាជ្យ និងមិនលម្អៀង។ ក្រុមមេធាវីការពារក្តីបានលើកការជំទាស់ទាំងអស់នេះ

---

[29] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Milosevic "សំអាងហេតុសម្រាប់សេចក្តីសម្រេចលើបណ្តឹងសាទុក្ខ បន្ទាន់បង្ខំរបស់រដ្ឋអាជ្ញាកើតចេញពីការបដិសេធក្នុងការចេញដីកាបញ្ចូលរួមគ្នា" ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២ កថាខណ្ឌ ១៩ ដល់ ២១។

[30] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Mladic សំណុំរឿងលេខ "សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញារួមក្នុង ការអនុវត្តដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក្នុងការបើកការជំនុំជម្រះក្តីដាច់ដោយឡែកពីគ្នា និងក្នុងការ កែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១ ("សេចក្តីសម្រេចលើករណី Mladic") កថាខណ្ឌ ២៨។

ចំពោះការបំបែកកិច្ចដំណើរការនីតិវិធីដែលបានសម្រេចសាជាថ្មី នៅក្នុងពេលសវនាការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[31]។

13. វិសាលភាពមានកម្រិតនៃសំណុំរឿង ០០២/០១ បានបង្កព្យសនកម្មដល់ នួន ជា យ៉ាងខ្លាំងជាទីបំផុត ដោយបានបង្អាក់លទ្ធភាពរបស់គាត់ក្នុងការឡើងការពារខ្លួនឲ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាព។ គោលនយោបាយទាំងឡាយដែល នួន ជា ត្រូវបានចោទប្រកាន់ថាអនុវត្តនៅក្នុងសំណុំរឿង ០០២/០១ គឺជា "ផ្នែកមួយនៃកិច្ចប្រឹងប្រែងខ្លាំងជាងក្នុងការរៀបចំសណ្តាប់ធ្នាប់ឡើងវិញចំពោះប្រទេសមួយ និងសេដ្ឋកិច្ចមួយដែលរងនូវការបំផ្លិចបំផ្លាញដោយសារសង្គ្រាម និងនាំមកនូវឯករាជ្យភាពចំពោះប្រជាជនដែលស្ថិតក្រោមវិធាននៃការត្រួតត្រា និងអំណាចអាណានិគមបរទេសអស់រយៈពេលជាច្រើនឆ្នាំ"[32]។ ដើម្បីធ្វើការវាយតម្លៃលើចេតនារបស់ នួន ជា ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់ ដែលជាការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ អង្គជំនុំជម្រះសាលាដំបូងនឹងត្រូវបានស្នើសុំឲ្យធ្វើការសម្រេចថាអ្វីដែល នួន ជា សង្ឃឹមទុកថានឹងកើតចេញពីគោលនយោបាយទាំងអស់នោះ។ ពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មទាំងឡាយដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១ ផែនការនោះ "មិនបានបញ្ចប់នៅត្រឹមគោលដៅរបស់អ្នកដែលត្រូវបានជម្លៀសនោះទេ"[33]។ ហេតុនេះ ត្រូវតែធ្វើការពិចារណាទៅលើផែនការនេះទាំងមូលតែម្តង។

14. ទស្សនៈទូលំទូលាយនេះមិនមានចំពោះ នួន ជា នៅក្នុងក្របខណ្ឌចង្អៀតនៃសំណុំរឿង ០០២/០១ នេះទេ។ ទោះបីជាទាំងអង្គជំនុំជម្រះសាលាដំបូង ទាំងសហព្រះរាជអាជ្ញាលើកឡើងថា គោលនយោបាយដែលបានលើកឡើងទាំងប្រាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវមានការសួរដេញដោលដោយភាគីនានា កំណត់ហេតុបង្ហាញច្បាស់លាស់ថា លើកលែងតែសាក្សីដែលត្រូវបានជ្រើសរើសមុនជាក់លាក់ ការសួរដេញដោលផ្ទាល់តែងតែត្រូវបានកម្រិតត្រឹមតែប្រធានបទដែលស្ថិតក្រោមវិសាលភាពនៃសំណុំ

---

[31] ឯកសារលេខ **E-1/172.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី" ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ ("សវនាការរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធី (ថ្ងៃទី ២)") ទំព័រ ៤:៣-៨:១៨។

[32] សវនាការរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធី (ថ្ងៃទី ២) ទំព័រ ៤:៩-១២។

[33] សវនាការរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធី (ថ្ងៃទី ២) ទំព័រ ៤:១៩-២០។

រឿង ០០២/០១ តែប៉ុណ្ណោះ[34]។ ដោយសារតែអង្គហេតុនានាដែលហួសពីវិសាលភាពនោះ មានការទាក់ទិនទៅនឹងមេធាវីការពារក្ដីរបស់ នួន ជា ការបំបែកកិច្ចដំណើរការនីតិវិធីនៃការជំនុំជម្រះក្ដី មិនមានលក្ខណៈសមស្របទេ[35]។

15. ឧទាហរណ៍ជាក់ច្បាស់មួយស្ដីពីផលប៉ះពាល់នេះ ជាប់ពាក់ព័ន្ធនឹងទំនាក់ទំនងរវាងការជម្លៀសចេញពីទីក្រុងភ្នំពេញ និងឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់ថាត្រូវបានប្រព្រឹត្តឡើងនៅសហករណ៍ និងនៅការដ្ឋាននានា។ ក្រុមមេធាវីការពារក្ដីបានលើកឡើងនៅក្នុងសេចក្ដីសន្និដ្ឋានគតិយុត្តិបឋមថា "ការជម្លៀសដោយបង្ខំ" មិនមែនខុសច្បាប់នោះទេនៅក្នុងឆ្នាំ ១៩៧៥ និងថា អំពើឧក្រិដ្ឋដែលអាចមានចេញពីការជម្លៀសនេះអាស្រ័យទៅលើ (យ៉ាងហោចណាស់) ការវាយតម្លៃលើ "គោលបំណង

---

[34] *សូមមើល* ឯកសារលេខ **E-145** អនុស្សរណៈផ្ញើពីអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១១ ERN 00756549-00756551 ទំព័រ ២ ដល់ ៣។ ឯកសារលេខ **E-172/10** អនុស្សរណៈ ផ្ញើពីអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ ERN 00793936 (ដោយកំណត់ វិសាលភាពនៃសក្ខីកម្មពាក់ព័ន្ធនឹងសាក្សីសំខាន់ៗ)។ ឯកសារលេខ **E-172/27** អនុស្សរណៈផ្ញើពី អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២ ERN 00816394-0081635 (ស្រដៀងគ្នា)។ ឯកសារលេខ **E-1/173.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដី" ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ ERN 00890050-00890119 ទំព័រ ២២:៧-១១ ("សហព្រះរាជអាជ្ញាបាន កត់សម្គាល់ឃើញថា ការសួរចម្លើយក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ ត្រូវបានកម្រិតត្រឹម សាក្សីមួយចំនួនប៉ុណ្ណោះ)។ ឯកសារលេខ **E-1/177.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដី" ចុះថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០១៣ ERN 00899302-00899397 ទំព័រ ១៩:១៣-២១:១៣ ("ការជំទាស់ទៅនឹងបញ្ហាទាំងឡាយដែលហួសពីវិសាលភាពដែលត្រូវបានបដិសេធចោល ពីព្រោះ ពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធ)។ ឯកសារលេខ **E-1/159.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំ ជម្រះក្ដី" ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១៣ ERN 00879818-00879927 ទំព័រ ៩១:២២-៩៣:៩ (ស្រដៀងគ្នា)។ ឯកសារលេខ **E-1/150.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដី" ចុះថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១២ ERN 00870086-00870205 ទំព័រ ១:២៣-២:៥ (ប្រធានអង្គជំនុំជម្រះបានរំលឹក ដល់ភាគីនានាឲ្យសួរតែសំណួរដែលពាក់ព័ន្ធនឹងគោលនយោបាយជម្លៀសប្រជាជន និងរចនាសម្ព័ន្ធ រដ្ឋបាលប៉ុណ្ណោះ)។ ឯកសារលេខ **E-1/35.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដី" ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១២ ERN 00775428-00775523 ទំព័រ ៥៩:១៣-១៩ (មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបានកត់សម្គាល់ឃើញថា បញ្ហាទាំងឡាយត្រូវបានចោទសួរតែសម្រាប់គោលបំណងនៃ រចនាសម្ព័ន្ធដែលបានបង្កើតឡើងប៉ុណ្ណោះ)។

[35] សេចក្ដីសម្រេចលើករណី Mladic កថាខណ្ឌ ៣៤។

លក្ខណៈនៃការអនុវត្ត និងផលប៉ះពាល់" នៃការជម្លៀស[36]។ ប្រជាជនដែលត្រូវបានជម្លៀសពីទីក្រុងភ្នំពេញ និងពីទីក្រុងផ្សេងៗទៀតបានលើកឡើងថាបានរស់នៅក្នុងសហករណ៍បន្ទាប់ពីការចាកចេញពីទីក្រុងរបស់ខ្លួន[37]។ នៅក្នុងខែ មេសា ឆ្នាំ ១៩៧៥ នួន ជា មានសំអាងហេតុត្រឹមត្រូវដែលនាំឲ្យជឿបានថា សហករណ៍ទាំងឡាយគឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការផលិតម្ហូបអាហារ និងការចែកចាយ ហើយវិធីសាស្ត្រនេះបានបង្កើញលទ្ធផលបែបនេះនៅតំបន់ជាច្រើនក្នុងប្រទេសកម្ពុជា[38]។ នួន ជា មិនអាចបញ្ជាក់ច្បាស់លាស់នូវការការពារជាប់លាប់ចំពោះការជម្លៀសដោយបង្ខំ ដោយគ្មានការវាយតម្លៃពិស្តារអំពីអ្វីដែលរំពឹងថានឹងកើតមាន និងបានកើតមានពិតប្រាកដ បន្ទាប់ពីការជម្លៀសនោះមក។

16. ឧទាហរណ៍មួយផ្សេងទៀតទាក់ទងនឹងធម្មានុរូបភាពនៃការគំរាមកំហែងដែលធ្វើឡើងដោយជនជាតិវៀតណាម មុនពេល និងក្នុងអំឡុងពេលរបបនោះ។ សាក្សីនានាបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងថា នួន ជា បានអនុវត្តគោលនយោបាយទាំងឡាយ "យ៉ាងឆាប់រហ័សប្រកបដោយគ្រោះថ្នាក់" (ហេតុនេះហើយ បានបណ្តាលឲ្យមានព្យសនកម្មដល់ប្រជាជនស៊ីវិលកម្ពុជា) ពីព្រោះគាត់ជឿជាក់ថា ការអភិវឌ្ឍសេដ្ឋកិច្ចលឿនមានសារៈសំខាន់ណាស់ដើម្បីបង្វែរមហិច្ឆតាវៀតណាមពាក់ព័ន្ធនឹងដែនដីកម្ពុជា[39]។ ធម្មានុរូបភាពនៃការគំរាមកំហែងនោះជាប់ពាក់ព័ន្ធទៅនឹងភាពចាំបាច់

---

[36] ឯកសារលេខ **E-163/5/11** "សេចក្តីសន្និដ្ឋានបឋមពាក់ព័ន្ធនឹងច្បាប់ជាធរមាន" ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ២៦ ដល់ ២៧។

[37] ឯកសារលេខ "ដីកាដំណោះស្រាយ" ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ("ដីកាដំណោះស្រាយ") កថាខណ្ឌ ១៦១ ("គោលបំណងមួយក្នុងចំណោមគោលបំណងនៃការផ្លាស់ទីលំនៅប្រជាជន គឺ ដើម្បីបំពេញលក្ខខណ្ឌការងាររបស់សហករណ៍ និងការដ្ឋាន")។

[38] *សូមមើលឧទាហរណ៍* ឯកសារលេខ **E-3/20** "នៅពេលដែលសង្គ្រាមបានកន្លងផុតទៅ" ទំព័រ ១៥០, ១៥៨។ ឯកសារលេខ **E-3/9** "ប៉ុល ពត៖ ប្រវត្តិនៃសុបិន្តអាក្រក់" ទំព័រ ២៩០។ ឯកសារលេខ **E-3/2412** "កម្ពុជា: សេដ្ឋកិច្ចបដិវត្ត" ទំព័រ ៦។ ឯកសារលេខ **D-153.13** "របាយការណ៍បញ្ជប់របស់ ប្រទេសកម្ពុជា" ទំព័រ ១៦ ដល់ ១៧ (ដោយពណ៌នាអំពីទិន្នផលស្រូវដែលគេសង្ឃឹមទុក នៅខែមេសា ឆ្នាំ ១៩៧៥)។ ឯកសារលេខ **E-131/1/15.1** "ប្រទេសកម្ពុជា: ភាពអត់ឃ្លាន និងបដិវត្តន៍" ទំព័រ ៨៥។

[39] *សូមមើលឧទាហរណ៍* សេចក្តីព្រាងប្រតិចារឹក ចុះថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ (សាក្សី Philip Short បានរៀបរាប់អំពី "ការប្រព្រឹត្តមិនសមរម្យ" របស់របបកម្ពុជាប្រជាធិបតេយ្យ ស្តីពី វៀតណាម)។

នៃគោលនយោបាយដែល នួន ជា ត្រូវបានចោទប្រកាន់ថាបានអនុវត្ត និងស្ថានភាពផ្លូវចិត្តរបស់គាត់ពាក់ព័ន្ធទៅនឹងបញ្ហានោះ។

17. សហព្រះរាជអាជ្ញាយល់ស្របថា ភ័ស្តុតាងបង្ហាញអំពីអំពើ និងគោលនយោបាយនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ មានសារៈប្រយោជន៍អាចឱ្យយើងយល់បានពេញលេញអំពីសម័យកម្ពុជាប្រជាធិបតេយ្យ[40]។ ក៏ប៉ុន្តែ ដោយមិនស្នើសុំឱ្យលើកឡើងបញ្ហាទាំងអស់នោះឱ្យបានពេញលេញនៅក្នុងវេទិកាសាធារណៈក្នុងពេលជំនុំជម្រះ សហព្រះរាជអាជ្ញាបានស្នើសុំអង្គជំនុំជម្រះសាលាដំបូងឱ្យទទួលយកចម្លើយរបស់សាក្សីអំពីបញ្ហានានា ដែលនៅក្រៅវិសាលភាពជាច្រើន ដោយពុំចាំបាច់ធ្វើការសួរដេញដោលឡើយ[41]។ ក្រុមមេធាវីការពារក្តីសូមជំទាស់យ៉ាងខ្លាំងលើការស្នើឡើងថា មានការតម្រូវឱ្យមានការជ្រើសរើសរវាងការយល់ស្របដោយមិនជំទាស់ទទួលយកសក្ខីកម្មដោយពុំធ្វើការសួរដេញដោល និងការទទួលយកសវនាការសួរដេញដោលពេញលេញលើអង្គហេតុពាក់ព័ន្ធនានា។ ដូច្នេះ ក្រុមមេធាវីការពារក្តីជំទាស់នឹងការទទួលយកចម្លើយទាំងអស់នោះ *ទាំងអស់តែម្តង*[42]។

18. ការលំបាកដូចគ្នានៅក្នុងការកំណត់លើផ្នែកនីមួយៗដាច់ពីគ្នានៅក្នុងដីកាដំណោះស្រាយ ក៏បណ្តាលឱ្យមានការបន្ថយលោភលើលទ្ធភាពរបស់ នួន ជា ក្នុងការតទល់ជាមួយនឹងសាក្សីដាក់បន្ទុកលើខ្លួនផងដែរ។ ផ្នែកដ៏សំខាន់មួយនៅក្នុងការជំនុំជម្រះលើសំណុំរឿង ០០២/០១ មានការពាក់ព័ន្ធទៅនឹងបញ្ហានៃការអនុវត្តជាទូទៅលើសំណុំរឿង ០០២ ទាំងមូល ដូចជា សាវតារប្រវត្តិសាស្ត្រ និងរចនាសម្ព័ន្ធយោធា

---

[40] ឯកសារលេខ **E-96/8** "សំណើបន្ថែមរបស់សហព្រះរាជអាជ្ញាដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះ សាលាដំបូងនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងប្រតិចារឹក ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ពី ១-១៦" ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ កថាខណ្ឌ ៣០-៣៤។

[41] ឯកសារលេខ **E-278** "សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាអំពីឧបសម្ព័ន្ធទី ១២ និងទី ១៣ ដែលបានកែសម្រួលឡើងវិញក្នុងបញ្ជីឯកសារសម្រាប់សវនាការរបស់ខ្លួន អនុលោមតាមវិធាន ៨០(៣) (កំណត់ហេតុស្តាប់ចម្លើយសាក្សី និងពាក្យបណ្តឹង)" ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ ២០១៣។ ឯកសារលេខ **E-278.2** "សេចក្តីសង្ខេបឧបសម្ព័ន្ធទី ១២ និងទី ១៣ ដែលត្រូវបានកែសម្រួល" ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣។

[42] ឯកសារលេខ **E-223/2/8** "ការជំទាស់ទៅនឹងសំណើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារឹក" ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ កថាខណ្ឌ ២០-៣៣។

រដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងនានា។ អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់សេរីភាពច្រើនដល់សហព្រះរាជអាជ្ញា ដើម្បីជជីកសួរសំណួរទាំងឡាយដែលនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ រួមទាំង មន្ទីរសន្តិសុខ សហករណ៍ និងការដ្ឋាននានា ក្រោមរូបភាពនៃការទាញយកសក្ខីកម្មនានាពាក់ព័ន្ធនឹង "រចនាសម្ព័ន្ធ"[43]។

19. ការដេញដោលលម្អិតលើភស្តុតាងទាំងនោះ អាចស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ ក៏ដូចជាការប្រើប្រាស់យុទ្ធសាស្ត្រមិនល្អមួយនៃពេលវេលាដែលបានលៃទុកសម្រាប់ក្រុមមេធាវីការពារក្ដី ដែលពេលវេលានេះមានតិចតួចណាស់។ ទោះជាយ៉ាងណាក្ដី ភស្តុតាងនោះមាននៅក្នុងសំណុំរឿង និងនៅចំពោះមុខអង្គជំនុំជម្រះ។ ប្រសិនបើភស្តុតាងទាំងនោះអាចទទួលយកបាននៅក្នុងសំណុំរឿង ០០២/០២ វានឹងធ្វើឱ្យមានការរំលោភលើសិទ្ធិរបស់ នួន ជា នៅក្នុងការតទល់ជាមួយនឹងសាក្សីដាក់បន្ទុកលើខ្លួន។ បើមិនដូច្នោះទេ សាក្សីទាំងអស់នោះចាំបាច់ត្រូវបានកោះហៅមក ដែលនឹងធ្វើឱ្យខូចខាតដល់គោលបំណងនៃការបំបែកកិច្ចដំណើរការនីតិវិធី ហើយវានឹងបង្កើតជាសំអាងហេតុក្នុងការជំនុំជម្រះតាមដីកាដំណោះស្រាយទាំងមូលតែម្ដង[44]។

20. ចំពោះសំអាងហេតុស្រដៀងគ្នានេះដែរ ទាំងការអាចគ្រប់គ្រងបានលើការជំនុំជម្រះ ទាំងដំណើរការរៀបរាប់ដែលត្រូវសម្រេច ក៏បានរងផលប៉ះពាល់ផងដែរ។ យើងឃើញថាមានការលំបាក និងចំណាយពេលច្រើននៅក្នុងការបំបែកផ្នែកដែលពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សីម្នាក់ៗពីសក្ខីកម្មដែលនៅក្រៅវិសាលភាព ដែលនាំឱ្យមានការជំទាស់ជារឿយៗពីភាគីនានា និងមានការប្រជុំពិភាក្សាសម្រេចជាញឹកញាប់ពីអង្គជំនុំជម្រះ[45]។ ប្រសិទ្ធភាពនៃកិច្ចប្រឹងប្រែងរបស់អង្គជំនុំជម្រះក្នុងការស្វែងរកការពិតក៏បានទទួលផលប៉ះពាល់ផងដែរ៖

[43] មានឧទាហរណ៍នៃការអនុវត្តបែបនេះជាច្រើននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដែលវិធានជា ធរមានអនុញ្ញាតឱ្យពិនិត្យលើសំនួរនៅក្រៅវិសាលភាពនៃការជំនុំជម្រះ ក្នុងករណីដែលសំនួរទាំងនោះ ត្រូវបានសន្មតថាពាក់ព័ន្ធនឹងរចនាសម្ព័ន្ធ។ ចំពោះឧទាហរណ៍ដែលត្រូវបានជ្រើសរើស សូមមើល លេខយោងជើងទំព័រទី ៣៤ *ដូចខាងលើ*។

[44] *សូមមើល* កថាខណ្ឌ ១១ *ដូចខាងលើ*។

[45] *សូមមើលឧទាហរណ៍* ត្រង់លេខយោងជើងទំព័រទី ៣៤ *ដូចខាងលើ*។

អ្វីដែលយើងបានស្ដាប់ឮនៅក្នុងតុលាការពុំមែនជារឿងរ៉ាវរៀបរាប់ជាក់លាក់ អំពីការផ្លាស់ទីលំនៅប្រជាជននោះទេ ហើយវាក៏ពុំមែនជារឿងរ៉ាវដែលងាយស្រួលយល់អំពីសម័យកម្ពុជាប្រជាធិបតេយ្យទាំងមូលនោះដែរ។ អ្វីដែលយើងស្ដាប់ឮគឺជាបំណែកនៃអង្គហេតុដែលគេសន្មតថាពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ តាមមធ្យោបាយមួយចំនួន ប៉ុន្តែរឿងរ៉ាវទាំងនេះមិនបានបង្ហាញពេញលេញអំពីអ្វីដែលពិតជាបានកើតឡើងពិតប្រាកដនោះទេ[46]។

21. ចំណុចចុងក្រោយ ការបំបែកកិច្ចដំណើរការនីតិវិធីដែលបានសម្រេចសារជាថ្មី ពុំមានលក្ខណៈសមស្របនោះទេ ពីព្រោះថាអង្គជំនុំជម្រះសាលាដំបូងពុំមានលទ្ធភាពបំពេញកិច្ចដោយមិនលម្អៀងនៅក្នុងសំណុំរឿង ០០២/០២ ក្រោយពេលចេញសាលក្រមលើសំណុំរឿង ០០២/០១ នោះឡើយ[47]។ អង្គជំនុំជម្រះតុលាការកំពូលបានបង្ហាញអំពីបញ្ហានេះដូចគ្នា និងបានផ្ដល់យោបល់ថា ក្រុមប្រឹក្សាជំនុំជម្រះដោយឡែកមួយក្រុមទៀតនៃអង្គជំនុំជម្រះសាលាដំបូង អាចចាំបាច់ត្រូវបង្កើតឡើង ដើម្បីធ្វើការវិនិច្ឆ័យលើសំណុំរឿង ០០២/០២[48]។ ពុំឃើញមានការបង្ហាញណាមួយថា ក្រុមប្រឹក្សាជំនុំជម្រះក្រុមទីពីរនឹងត្រូវបង្កើតឡើងនោះឡើយ រីឯគ្រប់ភាគីទាំងអស់បានយល់ស្របគ្នានៅក្នុងអំឡុងពេលនៃសវនាការស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីថា ការបង្កើតក្រុមប្រឹក្សាជំនុំជម្រះមួយក្រុមទៀតបែបនេះពុំទំនងជាអាចបង្កើតឡើងឡើយ[49]។ អង្គជំនុំជម្រះតុលាការកំពូលនៃសាលាក្ដី ICTY បានយល់ឃើញស្រដៀងគ្នាថា តុលាការគួរចៀសវាងកុំបំបែកបទចោទដាក់បន្ទុកលើជនជាប់ចោទណាមួយនៅក្នុងការជំនុំជម្រះជាបន្តបន្ទាប់ឲ្យសោះ ដើម្បីចៀសវាងកុំឲ្យមានការលេចចេញនូវភាពលម្អៀង[50]។

<u>ii. អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណាលើការជំទាស់របស់ក្រុមមេធាវីការពារក្ដី</u>

[46] សវនាការរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធី (ថ្ងៃទី ២) ទំព័រ ៧:៥-៩។

[47] សវនាការរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធី (ថ្ងៃទី ២) ទំព័រ ៧:២១-៨:១៨។

[48] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធី (ថ្ងៃទី ២) កថាខណ្ឌ ៥១។

[49] ឯកសារលេខ **E-1/171.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ("សវនាការរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធី (ថ្ងៃទី ១)" ទំព័រ ៩៥:១១-១៧ ទំព័រ ១០១:២២-១០២:៧)។

[50] សាលដីកាលើករណី Mladic កថាខណ្ឌ ៨៦-៨៧។

22. បើទោះជាអង្គជំនុំជម្រះតុលាការកំពូលបានណែនាំយ៉ាងច្បាស់លាស់ឲ្យស្តាប់ភាគីនានា និងផ្តល់សំអាងហេតុលើសេចក្តីសម្រេចរបស់ខ្លួនក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានខកខានយ៉ាងជាក់ស្តែងនៅក្នុងការដោះស្រាយចំពោះការជំទាស់ទាំងនេះ។ អង្គជំនុំជម្រះសាលាដំបូងក៏បានសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសាជាថ្មី នៅក្នុងកថាខណ្ឌចំនួន ៣ នៃសេចក្តីសម្រេចដែលមានចំនួន ៧០ ទំព័រ ក្នុងនោះ កថាខណ្ឌពីរដំបូងបានបញ្ជាក់សាជាថ្មីអំពីសំអាងហេតុដើមដែលបានសម្រេចបំបែកកិច្ចដំណើរការជំនុំជម្រះ[51]។ បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា៖

> ពាក់ព័ន្ធនឹងការជំទាស់ថ្មីៗពីសំណាក់មេធាវីការពារក្តី អំពីទស្សនៈនៃការបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កង្វល់ដែលមេធាវីការពារក្តីបានលើកឡើងទាក់ទងនឹងសច្ចៈភាពផ្លូវច្បាប់ ក្រោយពីការលុបចោលដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីដែលបានចេញនៅក្នុងដំណាក់កាលចុងក្រោយនៃដំណើរការនីតិវិធីសំណុំរឿង ០០២/០១ នោះ គឺជាក្តីកង្វល់សមស្របតាមផ្លូវច្បាប់។ ក៏ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា កង្វល់ទាំងនេះមិនអាចត្រូវបានដោះស្រាយ តាមរយៈការធ្វើសវនាការតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះនៃសំណុំរឿង ០០២ ទាំងមូលបានឡើយ ប៉ុន្តែអាចដោះស្រាយបានដោយការវិលទៅរកទម្រង់ដើមនៃសំណុំរឿង ០០២/០១ និងការបន្តកិច្ចដំណើរការនីតិវិធីស្របតាមដែនកំណត់នៃការជំនុំជម្រះ ដែលភាគីទាំងអស់យល់ដឹងអំពីការជំនុំជម្រះនេះតាំងពីដើមដំបូងរួចមកហើយ[52]។

23. មិនមានលក្ខណៈច្បាស់លាស់ថាតើការជំទាស់ណាមួយរបស់ក្រុមមេធាវីការពារក្តី ប្រសិនបើមានដែលមាន "ការព្រួយបារម្ភ [...] ពាក់ព័ន្ធនឹងសច្ចៈភាពគតិយុត្តិ" នោះទេ ក៏ប៉ុន្តែ វាបង្ហាញច្បាស់ថា សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា កង្វល់ទាំងនេះ "អាចដោះស្រាយបាន [...] ដោយការវិលទៅរកទម្រង់ដើមនៃសំណុំរឿង ០០២/០១" ខកខានពុំបានបញ្ជាក់ហេតុផលណាមួយគាំទ្រលើសេចក្តីសន្និដ្ឋាននោះឡើយ។ អង្គជំនុំជម្រះសាលាដំបូងពុំបានពន្យល់ថា តើផលប្រយោជន៍

---

[51] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ៨៨។

[52] សាលដីកាលើករណី Mladic កថាខណ្ឌ ៣៥។

របស់ នួន ជា ក្នុងការបង្ហាញការការពារខ្លួន ឬការតទល់លើភ័ស្តុតាងដាក់បន្ទុករបស់ខ្លួន ត្រូវបានការពារយ៉ាងដូចម្តេចនៅក្នុងបរិបទនៃការជំនុំជម្រះដែលត្រូវបានបំបែកកិច្ចដំណើរការនីតិវិធីនេះយ៉ាងដូចម្តេច ហើយអង្គជំនុំជម្រះសាលាដំបូងក៏ពុំបានពន្យល់ថា តើហេតុអ្វីបានជាផលប្រយោជន៍ក្នុងការរៀបចំការបំបែកកិច្ចដំណើរការនីតិវិធីនេះមានតម្លៃជាងផលប៉ះពាល់នៃការធ្វើដូច្នេះនោះ។ អង្គជំនុំជម្រះសាលាដំបូងក៏ពុំបានពិចារណាថាតើចាំបាច់ត្រូវបង្កើតក្រុមប្រឹក្សាជំនុំជម្រះក្រុមទីពីរដែរឬអត់នោះទេ ថាតើការបង្កើតក្រុមប្រឹក្សាជំនុំជម្រះនេះអាចទៅរួចក៏អត់នោះទេ ឬក៏ថាតើអង្គជំនុំជម្រះសាលាដំបូងនឹង "ធានា" មិនឲ្យមានភាពលម្អៀងដោយរបៀបណា ប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះក្រុមទីពីរមិនត្រូវបានបង្កើតឡើងទេ[53]។

24. ក្រុមមេធាវីការពារក្តីយល់ស្របដូចគ្នាជាមួយនឹងសហព្រះរាជអាជ្ញាដោយបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងមិនបានគោរពតាមការណែនាំរបស់អង្គជំនុំជម្រះ"ឲ្យបង្កើតនូវផែនការជាក់ស្តែងសម្រាប់ការជំនុំជម្រះដែលនៅសេសសល់នាពេលអនាគត" នោះទេ[54] ។ ដូចសហព្រះរាជអាជ្ញាបានសង្កេតឃើញដែរ អង្គជំនុំជម្រះនេះបានបង្គាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងផ្តល់បញ្ជីបន្ថែមក្រៅពីបញ្ជីស្តីពីបទចោទដែលត្រូវដេញដោលនៅក្នុងពេលជំនុំជម្រះនាពេលបន្តបន្ទាប់។ ជាពិសេស អង្គជំនុំជម្រះនេះបានណែនាំឲ្យអង្គជំនុំជម្រះសាលាដំបូងលើកឡើងអំពីការព្រួយបារម្ភជាក់ស្តែង ដែលភាគីដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាបានលើកឡើង[55]។ ជាការសមហេតុផល ការណែនាំនេះក៏អនុវត្តចំពោះការព្រួយបារម្ភដែលក្រុមមេធាវីការពារក្តីបានលើកឡើងជាបន្តបន្ទាប់ នៅក្នុងសវនាការលើដីកាបំបែកកិច្ចដំណើរការនីតិវិធីផងដែរ។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធមិនព្រមអនុវត្តតាមការណែនាំនេះទេ[56]។

---

[53] សាលដីកាលើករណី Mladic កថាខណ្ឌ ៧៧។

[54] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៧៧។

[55] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការបំបែកកិច្ចដំណើរការនីតិវិធី កថាខណ្ឌ ៤៧។

[56] សេចក្តីសម្រេចដែលត្រូវបានជំទាស់ កថាខណ្ឌ ១៥៥ (ដែលស្នើសុំឲ្យមានកិច្ចប្រជុំរៀបចំសវនាការដើម្បីដោះស្រាយការព្រួយបារម្ភមួយចំនួនដែលត្រូវបានលើកឡើងដោយសហព្រះរាជអាជ្ញា)។

???????????????????????

iii. សំណាងតែមួយគត់គឺមោឃភាពសេចក្តីសម្រេចដែលត្រូវបានជំទាស់

25. ផលប៉ះពាល់នៃការខកខានទាំងនេះ គឺមោឃភាពសេចក្តីសម្រេចបំបែកការជំនុំជម្រះ។ ក្នុងអំឡុងរយៈពេល១៨ខែនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងមិនអាចប្រើឧបាយកលជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ ឲ្យស៊ីសង្វាក់ជាមួយនឹងសិទ្ធិរបស់ នួន ជា ដើម្បីទទួលការជំនុំជម្រះដោយយុត្តិធម៌នោះទេ។ ករណីនេះ មិនទំនងជាមានការប្រែប្រួលនោះទេ។ នៅពេលដែលសំណុំរឿង០០២/០២ ចាប់ផ្តើមជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូងនឹងជួបនូវបញ្ហាទាំងអស់នេះជាលើកទីពីរ។ អង្គជំនុំជម្រះតុលាការកំពូល គួរតែសម្រេចដើម្បីបញ្ចប់នូវការពិភាក្សា និងភាពមិនច្បាស់លាស់នៅពេលឥឡូវនេះ និងគួរតែអនុវត្តតាមវិធីដែលសាមញ្ញបំផុត និងដោយមិនមានការប្រឆាំង ពោលគឺជំនុំជម្រះលើដីកាដំណោះស្រាយក្នុងសំណុំរឿង០០២ទាំងមូល ដោយសារតែសហចៅក្រមស៊ើបអង្កេតបានរៀបចំដីកាដំណោះស្រាយនេះ បន្ទាប់ពីការស៊ើបអង្កេតអស់រយៈពេលបីឆ្នាំ។ ហេតុដូច្នេះអង្គជំនុំជម្រះនេះគួរតែមោឃភាពសេចក្តីសម្រេចបំបែកការជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូងដែលអាចរារាំងដល់ដល់ការបំបែកសំណុំរឿងសាជាថ្មី។

26. អង្គជំនុំជម្រះនេះ គួរតែបង្គាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការជំនុំជម្រះតែមួយលើកចំពោះដីកាដំណោះស្រាយទាំងមូល ដោយសារតែមូលហេតុបន្ថែមនិងតែមួយគត់ដែលថា អង្គជំនុំជម្រះសាលាដំបូងមិនអាចសម្រេចទៅលើការជំនុំជម្រះលើកទីពីរនៅក្នុងសំណុំរឿង០០២/០២ បន្ទាប់ពីចេញសាលក្រមសំណុំរឿង០០២/០១នោះទេ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានសង្កេតយ៉ាងត្រឹមត្រូវ "មិនមានមូលដ្ឋានគតិយុត្តិ" ដើម្បីធ្វើជាយុត្តិកម្មក្នុងការបដិសេធចោលផ្នែកនៃការចោទប្រកាន់ ដើម្បីគាំទ្រដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលត្រូវបានកែសម្រួលនោះទេ[57]។ អង្គជំនុំជម្រះតុលាការកំពូល បានទទួលស្គាល់ការពិតនោះ ដោយបានចេញសេចក្តីណែនាំរបស់ខ្លួនជូនដល់អង្គជំនុំជម្រះសាលាដំបូងដើម្បីរៀបចំផែនការសម្រាប់វិនិច្ឆ័យទៅលើគុយ្យភាពនៃដីកាដំណោះស្រាយ។ ចាប់តាំងពី

---

[57] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ១៥២។

មានការជំនុំជម្រះជាបន្តបន្ទាប់ មិនស៊ីសង្វាក់គ្នាជាមួយនឹងសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយឥតលម្អៀង វាមានន័យថា អង្គជំនុំជម្រះត្រូវបានតម្រូវឱ្យស្តាប់សក្ខីកម្មនៃដីកាដំណោះស្រាយទាំងមូល។

27. ជាចុងក្រោយ សេចក្តីណែនាំរបស់អង្គជំនុំជម្រះនេះ សុំឱ្យដាក់សារណា ចេញសំអាងហេតុក្នុងសេចក្តីសម្រេចរបស់ខ្លួន និងស្នើសុំផែនការសម្រាប់ធ្វើការវិនិច្ឆ័យទៅលើតុយ្យភាពនៃដីកាដំណោះស្រាយ មិនមែនអនុវត្តតែទៅលើវិសាលភាពនៃសំណុំរឿង០០២/០១នោះទេ ប៉ុន្តែក៏អនុវត្តទៅលើសេចក្តីសម្រេចត្រង់ចំណុចថាតើការបំបែកកិច្ចដំណើរការនីតិវិធី មានលក្ខណៈសមស្របចាប់តាំងពីដំបូងដែរឬយ៉ាងណា[58]។ ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការចាត់វិធានការណាមួយ ទាក់ទិននឹងសេចក្តីសម្រេចបំបែកការជំនុំជម្រះ គឺជាការភ័ន្តច្រឡំអង្គច្បាប់ ដែលធ្វើឱ្យមោឃភាពសេចក្តីសម្រេចដែលរងការជំទាស់។

**គ. អង្គជំនុំជម្រះសាលាដំបូង បានភ័ន្តច្រឡំអង្គហេតុ ឬបានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួនដោយខកខានមិនបានបញ្ចូលបទចោទដែលទាក់ទិននឹងអំពើប្រល័យពូជសាសន៍ និងសហករណ៍និងការដ្ឋាននៅក្នុងសំណុំរឿង០០២/០១**

28. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "ច្បាស់ណាស់ [...] តាំងពីដំបូង ទោះជាមានតែប្រភេទនីមួយៗនៃទីតាំងឧក្រិដ្ឋកម្ម ឬការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់មនុស្សធម៌ក៏ដោយ ក៏ការបញ្ចប់រឿងក្តីនេះនៅក្នុងពេលជនជាប់ចោទមានជីវិតរស់នៅ ឬនៅពេលពួកគាត់នៅមានសម្បទា និងបញ្ញាស្មារតីក្នុងការចូលរួមសវនាការបាននោះ គឺជាការមួយដែលលំបាកបំផុតក្នុងការធ្វើឱ្យសម្រេច"[59]។ ផ្អែកលើមូលដ្ឋាននេះ អង្គជំនុំជម្រះបានសន្និដ្ឋានថា "ក្នុងការទទួលបានសាលក្រមទាន់ពេលវេលាក្នុងសំណុំរឿង ០០២ ហើយការណ៍នេះអាចសម្រេចបាននូវវិធានការសំខាន់អំពីភាពជាតំណាង

---

[58] សេចក្តីសម្រេចលើការបំបែកសំណុំរឿងរបស់ អ.ជ.ត.ក កថាខណ្ឌ៥០ (សេចក្តីសម្រេចរបស់អ.ជ.ត.ក ពុំបានធ្វើឱ្យប៉ះពាល់ដល់ការវាយតម្លៃឡើងវិញរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកសំណុំរឿង០០២ ដោយថិតនៅក្រោមលក្ខខណ្ឌដែលមានចែងនៅក្នុងសេចក្តីសម្រេចនោះ។

[59] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ១០៩។

នៃបទចោទរួម និងការចោទប្រកាន់លើអង្គហេតុនៅក្នុងដីកាដំណោះស្រាយ"[60]។ អង្គជំនុំជម្រះបាន លើកឡើងសាជាថ្មីថា សំណុំរឿង០០២/០១ មានមុនពេលមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនេះ ទោះបីជាអង្គជំនុំជម្រះទទួលស្គាល់ថា សំណុំរឿងនេះ មិនបានតំណាងឲ្យដីកាដំណោះស្រាយទាំងស្រុង នោះទេ[61]។

29. អង្គជំនុំជម្រះសាលាដំបូងបានខកខានយ៉ាងច្បាស់ដើម្បីបំពេញកិច្ចខិតខំប្រឹងប្រែងស្របច្បាប់ណាមួយ ដើម្បីរៀបចំការជំនុំជម្រះតំណាងសមហេតុផលមួយនៅក្នុងសំណុំរឿង០០២/០១។ ភាពច្បាស់លាស់ របស់អង្គជំនុំជម្រះដែលថា ការជំនុំជម្រះបែបនេះ មិនអាច"នឹង" សម្រេចនៅពេលជនជាប់ចោទមាន ជីវិតរស់នៅ គឺមិនអាចជឿជាក់បានទេ ដោយសារតែភាពមានជីវិតរស់នៅរបស់ នួន ជា គឺមិនអាច ទស្សន៍ទាយជាមុនបាននោះទេ។ មិនមានភ័ស្តុតាងណាមួយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង បង្ហាញឲ្យឃើញថា ជីវិត ឬសម្បទាដើម្បីចូលរួមក្នុងការជំនុំជម្រះរបស់ នួន ជា គឺមានគ្រោះថ្នាក់ នាពេលខាងមុខឆាប់ៗនោះទេ[62]។ អង្គជំនុំជម្រះសាលាដំបូងត្រូវបានតម្រូវឲ្យថ្លឹងថ្លែងស្ថានភាព សុខភាពរបស់គាត់ទៅនឹងថិរវេលារំពឹងទុកនៃការវិនិច្ឆ័យក្នុងពេលជំនុំជម្រះដែលបានស្នើសុំដោយ ភាគី។ អង្គជំនុំជម្រះបានខកខានក្នុងការធ្វើការថ្លឹងថ្លែងបែបនេះ ដូច្នេះអង្គជំនុំជម្រះបានរំលោភលើ ឆន្ទានុសិទ្ធិរបស់ខ្លួន។

30. តាមរយៈការបង្ហាញឲ្យឃើញថា ការសន្និដ្ឋានរបស់អង្គជំនុំជម្រះ "ច្បាស់លាស់ [...] តាំងតែពីដំបូង" អង្គជំនុំជម្រះសាលាដំបូង បានយល់ស្របថា ខ្លួនបានខកខានមិនបានពិនិត្យឡើងវិញការវិភាគរបស់ខ្លួន ដោយពិចារណាលើលក្ខខណ្ឌតម្រូវនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនេះ។ អង្គជំនុំជម្រះសាលា

---

[60] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ១២១។ *សូមមើលផងដែរ ដូចជើងទំព័រខាងលើ* កថាខណ្ឌ ១១២ ("[ជនរងគ្រោះ] ភាគច្រើន ត្រូវបានដកចេញដោយមិនអាចជៀសបាន")។

[61] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ១១១-១១៣, ១១៨-១១៩ (កត់សម្គាល់ឃើញថា សំណុំរឿង០០២/០១ មិនបានរួម បញ្ចូលវិសាលភាពពេលវេលា ឬភូមិសាស្ត្រពេញលេញនៃដីកាដំណោះស្រាយ ឬប្រភេទទាំងអស់នៃបទល្មើសដែលត្រូវបានចោទ ប្រកាន់ ដែលអង្គជំនុំជម្រះសម្រេចមិនជ្រើសរើសរវាង "ចំណុចនានាជាច្រើនដែលសក្តិសមដូចៗគ្នាសម្រាប់ដាក់បញ្ចូលទៅក្នុង វិសាលភាពនៃការជំនុំជម្រះ" ជាមួយនឹង ជនរងគ្រោះភាគច្រើនត្រូវបានដកចេញ "ដោយមិនអាចជៀសបាន")។

[62] *សូមមើល* បណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកសំណុំរឿងលើកទីពីរ កថាខណ្ឌ៦១-៦៣។

ដំបូងបានបង្ហាញពីមុនថា ការតំណាង គឺមិនពាក់ព័ន្ធទាល់តែសោះទៅនឹងការបង្កើតវិសាលភាពនៃសំណុំរឿង០០២/០១[63]។ សេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាមានភាពពាក់ព័ន្ធគួរតែជម្រុញឲ្យមានការពិចារណាសាជាថ្មីទៅលើការវាយតម្លៃខាងដើមរបស់ខ្លួនទៅលើវិសាលភាពនៃសំណុំរឿង០០២/០១ ដោយពិចារណាទៅលើអាយុ និងសុខភាពរបស់ជនជាប់ចោទ។ អង្គជំនុំជម្រះសាលាដំបូងគួរតែពិចារណាថាតើមរណភាពរបស់ អៀង សារី បានកែប្រែគម្រោងពេលវេលាដែលការជំនុំជម្រះលើកទីមួយ គួរតែត្រូវបានបញ្ចប់សព្វគ្រប់ដែរឬយ៉ាងណា។ ប៉ុន្តែ អង្គជំនុំជម្រះបែរជាគោរពតាមសេចក្តីសម្រេចដើមរបស់ខ្លួនទៅវិញ។

31. ផ្អែកលើសំអាងហេតុទាំងនេះ អង្គជំនុំជម្រះសាលាដំបូងបានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួនដោយសារតែខកខានមិនបានផ្តល់នូវការពិចារណាណាមួយទៅលើលទ្ធភាពនៃការធ្វើការជំនុំជម្រះដែលតំណាងសមហេតុផលដល់ដីកាដំណោះស្រាយនៅក្នុងសំណុំរឿង០០២/០១នោះទេ។ ការជំនុំជម្រះបែបនេះ គឺអាចធ្វើបានផង និងមានលក្ខណៈចាំបាច់ផង។ នៅកម្រិតអប្បបរមា អង្គជំនុំជម្រះគួរតែបញ្ចូលបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងនឹង នួន ជា និងផ្នែកចោទប្រកាន់ដែលទាក់ទងនឹងសហករណ៍ និងការដ្ឋាន។

i. <u>សំណុំរឿង០០២/០១ ត្រូវតែតំណាងសមហេតុផលនៃដីកាដំណោះស្រាយទាំងស្រុង</u>

32. ផ្អែកតាមសំអាងហេតុដូចគ្នាដែលថា អង្គជំនុំជម្រះនេះ គួរតែបដិសេធចោលការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២សាជាថ្មីរបស់អង្គជំនុំជម្រះសាដំបូង អង្គជំនុំជម្រះត្រូវធានាថា ប្រសិនបើដីកាដំណោះស្រាយត្រូវបានបំបែក ការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង០០២/០១ គឺត្រូវតែជាតំណាងដោយសមហេតុផលដល់សំណុំរឿង០០២ទាំងមូល។ នៅក្នុងបរិបទនៃការជំនុំជម្រះមួយចំនួន សិទ្ធិរបស់ នួន ជា ដើម្បីមានការការពារខ្លួនពេញលេញ និងប្រកបដោយប្រសិទ្ធិភាព និងសិទ្ធិដើម្បីតទល់នឹងភស្តុតាងប្រឆាំងលើរូបគាត់ អាចនឹងត្រូវបានការពារ តាមរយៈការជំនុំជម្រះក្តីដែលគ្រោបទាំងអស់នូវព្រឹត្តិការណ៍ធំៗ និងគោលនយោបាយទាំងអស់របស់កម្ពុជាប្រជាធិបតេយ្យ។

[63] សេចក្តីសម្រេចលើសំណើសុំឲ្យពិចារណាឡើងវិញ កថាខណ្ឌ៩។

33. នួន ជា ទទួលបានសិទ្ធិដើម្បីជំទាស់ទៅនឹងការចោទប្រកាន់ទាំងអស់ដែលប្រឆាំងលើរូបគាត់។ ដូចដែលមេធាវីការពារក្ដីតវ៉ាចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដីកាដំណោះស្រាយគឺជាការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះតាមផ្លូវតុលាការ ដែលចាត់ទុកថា នួន ជា គឺ "ប្រហែលជា" មានពិរុទ្ធភាពនៃបទល្មើសអន្តរជាតិធ្ងន់ធ្ងរជាច្រើន[64]។ ផ្នែកណាមួយនៃដីកាដំណោះស្រាយដែលមិនបានជំនុំជម្រះនៅក្នុងសវនាការ "នឹងក្លាយជាការវិនិច្ឆ័យស្លាពទៅលើការទទួលខុសត្រូវឧក្រិដ្ឋកម្មរបស់ នួន ជា ចំពោះព្រឹត្តិការណ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"[65]។ នួន ជា ស្ទើរតែមិនត្រូវបានផ្ដល់សិទ្ធិអ្វីទាំងអស់អំពីការចូលរួមនៅក្នុងការស៊ើបអង្កេតរបស់តុលាការ[66]។ ដូច្នេះ ការបន្តការជំនុំជម្រះ គឺជា "ឱកាសរបស់គាត់តែមួយប៉ុណ្ណោះដើម្បីបង្ហាញការការពារខ្លួនគាត់ទៅនឹងការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ" និងសម្រាប់ឲ្យសាធារណជនកម្ពុជាបានស្ដាប់អំពីការពិតនៃប្រវត្តិសាស្ត្រ[67]។

34. សហព្រះរាជអាជ្ញាលើកទឡ្ហីករណ៍ថា លទ្ធភាពនៃការជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២ គឺ "មិនអាចធ្វើទៅកើត" នោះទេ ហើយបទចោទដែលមិនបានបញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ នឹងត្រូវបាន "បញ្ចប់ប្រកបដោយប្រសិទ្ធិភាព"[68]។ ប៉ុន្តែសហព្រះរាជអាជ្ញាមិនបានរៀបរាប់លំអិតថាតើហេតុអ្វីបានជាវិសាលភាពនៃសំណុំរឿង០០២/០១ គួរតែត្រូវបានកំណត់ឲ្យចង្អៀតត្រឹមការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំនៅដំណាក់ទី១ និងទី២, ទួលពោធិ៍ជ្រៃ និងមន្ទីរស-២១ តែប៉ុណ្ណឹង។ ដូចដែលអង្គជំនុំជម្រះនេះបានទទួលស្គាល់ លទ្ធភាពដែលមិនមានការជំនុំជម្រះណាមួយ

---

[64] ដីកាដំណោះស្រាយ កថាខណ្ឌ១៣២៣ (បទដ្ឋាននៃការចោទប្រកាន់ជនជាប់ចោទ គឺប្រហែលជាមានពិរុទ្ធភាពប៉ុណ្ណោះ មិនមែនអាចមានលទ្ធភាពថាមានពិរុទ្ធភាពនោះទេ។

[65] សវនាការស្ដីពីការបំបែកសំណុំរឿងរបស់អ.ជ.ត.ដ (ថ្ងៃទី២) ទំព័រ ៣:២២-២៣។

[66] *សូមមើល ឧទា.* ឯកសារលេខ A110 អនុស្សរណៈរបស់សហចៅក្រមស៊ើបអង្កេតផ្ញើជូនមេធាវី នួន ជា ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៨។

[67] សវនាការស្ដីពីការបំបែកសំណុំរឿងរបស់អ.ជ.ត.ដ (ថ្ងៃទី២) ទំព័រ ៣:២៤-៤:២។

[68] បណ្ដឹងសាទុក្ខប្រឆាំងនឹងការបំបែកសំណុំរឿងលើកទីពីរ កថាខណ្ឌ២៤។

ទៀតនាពេលខាងមុខ រារាំងចំពោះ "ការតំណាងជាអតិបរមា" នៃបទចោទនៅក្នុងសំណុំរឿង ០០២/០១[69]។

35. វិសាលភាពទូលំទូលាយនៃសំណុំរឿង០០២/០១ គឺទំនងជាទទួលផ្លែផ្កាច្រើនជាងការជំនុំជម្រះលើកទីពីរនៅក្នុងសំណុំរឿង០០២/០២។ ប្រទេសផ្តល់ជំនួយ ទំនងជាអាចបដិសេធផ្តល់ជំនួយដល់ការជំនុំជម្រះលើកទីពីរ ជាងអ្វីដែលប្រទេសផ្តល់ជំនួយអនុញ្ញាតឲ្យសំណុំរឿង០០២/០១ បញ្ចប់ដោយគ្មានសាលក្រមណាមួយបន្ទាប់ពីមានកិច្ចដំណើរការនីតិវិធីអាចរយៈពេលជិតប្រាំមួយឆ្នាំ។ បន្ថែមពីលើនេះ សំណុំរឿង០០២/០២ អាចនឹងចាប់ផ្តើម ក្រោយពេលដែលចេញសាលក្រមក្នុងសំណុំរឿង ០០២/០១សិន ដែលទំនងពន្យារពេលជាច្រើនខែ[70]។ ការចោទប្រកាន់ដែលបញ្ចូលទៅក្នុងសំណុំរឿង ០០២/០១ អាចនឹងត្រូវបានស្តាប់សក្ខីកម្មភ្លាមៗ។

36. មិនមានហានីយភ័យណាមួយអាចនឹងកើតមានចំពោះសំណុំរឿង០០២/០១នោះទេ។ ដូចដែលសហព្រះរាជអាជ្ញាបានទទួលស្គាល់ សុខភាពរបស់ នួន ជា កំពុងតែមានសភាពនៅនឹងនរ[71]។ ការផ្តល់ថវិកាសម្រាប់ខាងផ្នែកអន្តរជាតិរបស់តុលាការ មិនដែលមានរអាក់រអួលនោះទេ ហើយជាការពិតបច្ចុប្បន្ននេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិកំពុងបន្ថែមបុគ្គលរបស់ខ្លួនដើម្បីស៊ើបអង្កេតសំណុំរឿង០០៣ និង០០៤។ នៅឆ្នាំ២០១២ រដ្ឋបាលតុលាការ បានបន្ថែមកញ្ចប់ថវិកា៣០%សម្រាប់ក្រុមមេធាវីការពារក្តីនីមួយៗ។

37. ប្រសិនបើការជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០២ ពិតជា "មិនអាចធ្វើទៅកើត" ដូចនេះភាពសំខាន់ដើម្បីធានាថា តំណាងពិតប្រាកដនៃដីកាដំណោះស្រាយត្រូវបានជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ គឺពិតជាត្រូវការខ្លាំង។ ដូចភាគីទាំងអស់ផ្សេងទៀត នួន ជា ចង់បានការជំនុំជម្រះពេញលេញមួយនៃ

---

[69] សេចក្តីសម្រេចលើការបំបែកសំណុំរឿងរបស់ អ.ជ.ត.ក កថាខណ្ឌ៤៣។

[70] សវនាការស្តីពីការបំបែកសំណុំរឿងរបស់អ.ជ.ត.ដ (ថ្ងៃទី២) ទំព័រ ២៣:១៧-២៤:២៣។

[71] បណ្តឹងសាទុក្ខប្រឆាំងនឹងការបំបែកសំណុំរឿងលើកទីពីរ កថាខណ្ឌ៦១-៦៣។

ដីកាដំណោះស្រាយ។ អង្គជំនុំជម្រះនេះ គួរតែខិតខំប្រឹងប្រែងដើម្បីធានាថាការជំនុំជម្រះពេញលេញមួយនឹងកើតមានឡើង។

ii – សំណុំរឿង ០០២/០១ ត្រូវតែបញ្ចូលបទចោទពីអំពើប្រល័យពូជសាសន៍

38. ដីកាដំណោះស្រាយចោទប្រកាន់ នួន ជា ពីការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះ "ការកំណត់អត្តសញ្ញាណ កំណត់មុខសញ្ញា ប្រមូលផ្ដុំ និងសម្លាប់បុគ្គល ដោយមានការគិតទុកជាមុន និងមានលក្ខណៈជាប្រព័ន្ធ" នូវប្រជាជនរាប់ម៉ឺននាក់ ដោយសារពួកគេជាសមាជិកនៅក្នុងក្រុមជាតិសាសន៍ ឬក្រុមសាសនាណាមួយ[72]។ ដីកាដំណោះស្រាយបានសន្និដ្ឋានថា គាត់មានចេតនាពិសេសដើម្បីបំផ្លាញក្រុមទាំងនោះ និងចង់បំផ្លាញពួកគេទាំងស្រុងតែម្ដង[73]។ ពុំមានការចោទប្រកាន់ណាខុសឆ្គងជាងការកំណត់បទល្មើសខុសឆ្គងចំពោះពួកខ្មែរក្រហម ឬ តួនាទីរបស់ នួន ជា ក្នុងនាមជាមេដឹកនាំម្នាក់របស់ពួកខ្មែរក្រហមនោះទេ។

39. ស្ថានទម្ងន់នៃបទចោទពីអំពើប្រល័យពូជសាសន៍តម្រូវថា អង្គជំនុំជម្រះនេះត្រូវយកចិត្តទុកដាក់ជាពិសេសក្នុងការធានាថា សិទ្ធិរបស់ នួន ជា ក្នុងការជំទាស់ទៅនឹងការចោទប្រកាន់ប្រឆាំងនឹងរូបគាត់ត្រូវតែគោរព។ ដីកាដំណោះស្រាយដែលត្រូវបានបញ្ជាក់ដោយតុលាការបានសន្និដ្ឋានថា នួន ជា "ប្រហែល" ជាបានប្រព្រឹត្តនូវឧក្រិដ្ឋកម្មដែលអាក្រក់បំផុតដល់មនុស្សជាតិ។ តុលាការនេះមិនអាចគ្រាន់តែសម្រាប់ថា បទចោទនោះមិនសំខាន់គ្រប់គ្រាន់ដើម្បីជំនុំជម្រះនោះទេ។ តុលាការនេះមិនអាចចេញ*សេចក្ដីសម្រេច*បានទូលំទូលាយប្រឆាំងនឹង នួន ជា ដែលថា គាត់*ប្រហែលជា*មានចេតនាបំផ្លាញក្រុមប្រជាជនទាំងស្រុងតែម្ដង។

72 ដីកាដំណោះស្រាយ, កថាខណ្ឌ ១៣៣៧, ១៣៤៤។

73 ដីកាដំណោះស្រាយ, កថាខណ្ឌ ១៣៣៨, ១៣៤៥។

40. នៅក្នុងគំនិតរបស់សាធារណជនវិញយល់ថា តួនាទីពិសេស និង មានបុព្វសិទ្ធិជុំវិញពាក្យថា "អំពើប្រល័យពូជសាសន៍" ដែលប្រើសម្រាប់កំណត់សម័យកាលខ្មែរក្រហមក៏មានសារៈសំខាន់ដូចគ្នាដែរ។ ស្ថាប័នដែលបង្កើតមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) និងដែលបានប្រមូលភស្តុតាងភាគច្រើនដល់តុលាការនេះគឺ "កម្មវិធីប្រល័យពូជសាសន៍នៅកម្ពុជា" របស់សាកលវិទ្យាល័យ Yale បានចាត់ទុកកម្ពុជាប្រជាធិបតេយ្យជាគំរូនៃអំពើប្រល័យពូជសាសន៍ប្រចាំសតវត្សរ៍ទី ២០ ថា៖

> អំពើប្រល័យពូជសាសន៍នៅកម្ពុជាពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ ដែលបណ្តាលឱ្យប្រជាជនយ៉ាងហោចណាស់ ១,៧ លាននាក់ស្លាប់បាត់បង់ជីវិត (២១% នៃប្រជាជនទូទាំងប្រទេស) គឺជាសោកនាដកម្មមួយដ៏អាក្រក់បំផុតសម្រាប់មនុស្សជាតិក្នុងសតវត្សរ៍កន្លងទៅ។ ដូចក្នុងចក្រភព Ottoman ក្នុងអំឡុងពេលមានអំពើប្រល័យពូជសាសន៍នៅអាមេនី ប្រទេសអាល្លឺម៉ង់ក្នុងសម័យណាហ្ស៊ី និងនាពេលថ្មីៗនេះនៅប្រទេសទីម័រខាងកើត ហ្គាតេម៉ាឡា យូហ្គោស្លាវី និងរ៉ូវ៉ាន់ដា ដែរ របបខ្មែរក្រហមដែលដឹកនាំដោយ ប៉ុល ពត រួមជាមួយមនោគមវិជ្ជាជ្រុលនិយមដែលចាត់ទុកជាសត្រូវជាតិសាសន៍ និងការប្រមាថជីវិតមនុស្សយ៉ាងអាក្រក់បំផុត បានបង្កើតឱ្យមានការគាបសង្កត់ ទុក្ខវេទនា និងការសម្លាប់មនុស្សជាទ្រង់ទ្រាយធំ[74]។

41. ផ្ទុយពីទស្សនៈរបស់សាធារណជនបែបនេះ អំពើប្រល័យពូជសាសន៍គឺជាបទឧក្រិដ្ឋមួយក្នុងចំណោមបទឧក្រិដ្ឋចំនួនតូចដែលមានការជំទាស់ពីសូម្បីតែអ្នកជំនាញដែលអយ្យការស្វែងរកជំនួយនេះដែរ[75]។ ទស្សនៈរបស់សាធារណជនអំពីតួនាទីនៃអំពើប្រល័យពូជសាសន៍នៅក្នុងរបបខ្មែរក្រហមនាំឱ្យប្រាប់ខុសនូវកំណត់ហេតុប្រវត្តិសាស្ត្រ ជាងការចោទប្រកាន់ណាមួយផ្សេងទៀតនៅក្នុងដីកាដំណោះស្រាយ។ តុលាការនេះ និងការប្រកាសរបស់ខ្លួនពីបទចោទនៃអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាប់ចោទ ត្រូវទទួលការស្តីបន្ទោសក្នុងការបង្កើតឱ្យមានទស្សនៈបែបនោះ។ នួន ជា មានសិទ្ធិ

---

74 "កម្មវិធីប្រល័យពូជសាសន៍នៅកម្ពុជា៖ The CGP ឆ្នាំ ១៩៩៤ ដល់ ២០០៣", អាចរកបាននៅឯគេហទំព័រ៖ http://www.yale.edu/cgp/។

75 សេចក្តីព្រាងប្រតិចារឹក, ថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០១៣, ទំព័រ ១៧:២៤ ដល់ ១៩:១១ (ភាសាអង់គ្លេស)។

ទទួលបានឱកាសក្នុងការបង្ហាញថាការចោទប្រកាន់ទាំងនោះមិនត្រឹមត្រូវ មានសិទ្ធិកែតម្រូវកំណត់ហេតុសាធារណៈ និងមានសិទ្ធិបង្ហាញថាគាត់មិនបានសម្លាប់ប្រជាពលរដ្ឋរបស់ខ្លួនទេ។

42. បទចោទពីអំពើប្រល័យពូជសាសន៍ក៏មានសំណួរដ៏សំខាន់បំផុត និងពិបាកយល់បំផុតដែរដែលតុលាការត្រូវប្រឈមមុននោះគឺ៖ តើអ្វីជាខ្លឹមសារនៃបដិវត្តន៍ខ្មែរក្រហម? អំពើប្រល័យពូជសាសន៍គឺគ្រាន់តែជាបទចោទមួយនៅក្នុងដីកាដំណោះស្រាយ ដែលអនុលោមទៅតាមបទចោទនានាដែល នួន ជា ត្រូវបានចោទប្រកាន់ថាមានចេតនាពិសេសក្នុងការសម្លាប់ប្រជាពលរដ្ឋរបស់ខ្លួនតែប៉ុណ្ណោះ។ ហេតុនេះសំណួរដែលគេនិយមសួរជាងគេគឺថា៖ ជាខ្លឹមសារ តើខ្មែរក្រហមជាចលនាដែលមានសុឆន្ទៈក្នុងការស្វែងរកការលើកស្ទួយកម្រិតជីវភាពរបស់ប្រជាជនកម្ពុជាឬ? ឬជាខ្លឹមសារ វាជារបបដែលសម្លាប់មនុស្ស និងគួរឲ្យស្អប់ខ្ពើមដែលបង្កើតឡើងដើម្បីលុបបំបាត់ក្រុមនានាដែលនៅក្រៅវណ្ណៈកសិករនៅតាមជនបទរបស់ខ្លួន? តាមផ្លូវច្បាប់ និងតាមសីលធម៌ សំណួរទាំងនោះជាសំណួរមូលដ្ឋានដើម្បីឲ្យយើងយល់ដឹងពីរបបកម្ពុជាប្រជាធិបតេយ្យ។ សវនាការដែលមិនបានយកចិត្តទុកដាក់ចំពោះសំណួរទាំងនោះមិនអាចមានភាពជាតំណាង ឬជាប្រយោជន៍នៃយុត្តិធម៌បានទេ។

43. អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ "ទស្សនៈនៃអំពើប្រល័យពូជសាសន៍ជាបទល្មើសធ្ងន់ធ្ងរបំផុតដែលអាចផ្តន្ទាទោសនៅចំពោះមុខ អ.វ.ត.ក" តែបានបដិសេធមិនបញ្ចូលបទចោទទាំងនោះទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ទេ ដោយសារវាមានកម្រិតត្រឹមតែ "ការសម្លាប់ប្រជាជនវៀតណាម និងប្រជាជនចាម"[76]។ សេចក្តីសន្និដ្ឋាននោះនាំឲ្យយល់ខុសពីតួនាទីនៃបទចោទពីអំពើប្រល័យពូជសាសន៍នៅក្នុងបរិបទរបស់ដីកាដំណោះស្រាយ ហើយហេតុនេះវាបណ្តាលឲ្យមានកំហុសឆ្គងលើអង្គហេតុ។

---

76 សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១១៣។

44. ដីកាដំណោះស្រាយបានចោទប្រកាន់ថា គោលនយោបាយជាគន្លឹះមួយក្នុងចំណោមគោលនយោបាយទាំង ៥ របស់របបកម្ពុជាប្រជាធិបតេយ្យគឺការកំណត់ជាគោលដៅនូវក្រុមនានាដើម្បី "បង្កើតឡើងនូវសង្គមមួយដែលមិនមានសាសនា រួបរួមគ្នាដោយមិនមានការបែងចែកវណ្ណៈ តាមរយៈការលុបបំបាត់ចោលភាពខុសគ្នារវាងជនជាតិ ជាតិ សាសនា សង្គម និងវប្បធម៌" [77]។ ក្នុងចំណោមក្រុមនានាដែលអះអាងថាត្រូវបានកំណត់ជាគោលដៅអនុលោមតាមគោលនយោបាយនោះគឺ "អ្នកប្រឆាំងនឹងបដិវត្តន៍" ដូចជាពួកសក្តិភូមិ ពួកនាយទុន និងអភិជន និង "ជនជាតិភាគតិចទាំងអស់"[78]។ ដោយវណ្ណៈទាំងនេះត្រូវ "លុបបំបាត់ [...] គឺមានតែវណ្ណៈកម្មករ និងកសិករប៉ុណ្ណោះដែលមានអត្ថិភាព ហើយថាវណ្ណៈទាំងអស់ដទៃទៀត ត្រូវបានរំលាយបញ្ចូលក្នុងវណ្ណៈទាំងពីរនេះ"[79]។

45. តាមវិធីនេះដដែល សហព្រះរាជអាជ្ញាចង់បង្ហាញថា គោលនយោបាយរបស់ ប.ក.ក បានចាត់ទុកអ្នកទីក្រុងថាជាខ្មាំងសត្រូវរបស់បក្ស និងបដិវត្តន៍ដូចក្រុមខាងលើដែរ[80]។ ទាហានខ្មែរក្រហមត្រូវបានអះអាងថាបានបង្ហាញការមិនគោរពទាល់តែសោះដល់ជីវិតរបស់ជនស៊ីវិលនៅក្រុងភ្នំពេញ និងទីប្រជុំជនផ្សេងៗទៀត[81]។ "ប្រជាជនថ្មី" បញ្ញវន្ត និស្សិត និងអ្នកការទូតរបស់សាធារណរដ្ឋខ្មែរដែលរស់នៅបរទេសត្រូវបានអះអាងថាត្រូវគេធ្វើបាបជាប្រព័ន្ធ ចាប់ខ្លួន*ជាទ្រង់ទ្រាយធំ* និងយកទៅសម្លាប់[82]។

---

[77] ដីកាដំណោះស្រាយ, កថាខណ្ឌ ២០៧។

[78] ដីកាដំណោះស្រាយ, កថាខណ្ឌ ២០៧។

[79] ដីកាដំណោះស្រាយ, កថាខណ្ឌ ២០៧។

[80] ឯកសារលេខ **E1/181.1**, "ប្រតិចារឹកនៃកិច្ចដំណើរការសវនាការ", ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៣, ទំព័រ ៥១:៧ ដល់ ១១ (ភាសាអង់គ្លេស); ឯកសារលេខ **E1/182.1**, "ប្រតិចារឹកនៃកិច្ចដំណើរការសវនាការ", ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣, ទំព័រ ៥:១៦ ដល់ ៦:៩ (ភាសាអង់គ្លេស)។

[81] សេចក្តីព្រាងប្រតិចារឹក, ថ្ងៃទី ៧ ខែ ឧសភា ឆ្នាំ ២០១៣, ទំព័រ ៦៨:១០ ដល់ ២៣ (ភាសាអង់គ្លេស)។

[82] ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤១៧ ដល់ ១៤១៨។

46. ការចោទប្រកាន់ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តទៅលើជនជាតិចាម និងវៀតណាមគឺជាចំណែកតូចមួយនៃគោលនយោបាយរបស់ខ្មែរក្រហមចំពោះអ្នកដែលត្រូវបានចោទប្រកាន់ថាមិនបរិសុទ្ធប៉ុណ្ណោះ។ លោក Steve Heder បានលើកឡើងជាទឡ្ហីករណ៍មិនត្រឹមត្រូវថា "ទាំងលទ្ធិម៉ាក្សនិយម និងកុម្មុយនីស្តនិយមជាឫសគល់នៃការប្រកាន់ពូជសាសន៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"[83]។ បើតាមលោក Heder គឺថា ក្រុមនានាដូចជាជនជាតិចាម និងវៀតណាមត្រូវបានកំណត់ជាគោលដៅ ដោយសារពួកខ្មែរក្រហមខិតខំ "បង្កើតទំនាក់ទំនងផលិតកម្មបែបសង្គមនិយម [...] បានបំផ្លាញប្រជាជនដែលវណ្ណៈភាពរបស់ខ្លួនត្រូវបានកំណត់ទៅតាមន័យនៃ "ជាតិសាសន៍" និង "ពូជសាសន៍""[84]។ ហេតុនេះបាតុភូតដែលនាំឱ្យមានការចោទប្រកាន់ជា "អំពើប្រល័យពូជសាសន៍" នៅក្នុងដីកាដំណោះស្រាយមិនត្រូវបានអះអាងថាសំដែងចេញនូវការរើសអើងចំពោះបដិវត្តន៍សង្គមនិយមដែលត្រូវបានលាតត្រដាងស្របគ្នានោះទេ។ ចំណុចនេះត្រូវបានចោទប្រកាន់ថាជាលក្ខណៈសម្គាល់ពីការខិតខំប្រឹងប្រែងនៃបដិវត្តន៍សង្គមនិយម ដើម្បីលុបបំបាត់ក្រុមនានាដែលគេចាត់ទុកថាមិននៅក្នុងប្រភេទវណ្ណៈដែលគេពេញចិត្ត។ មានតែលក្ខណៈសម្បត្តិតាមផ្លូវច្បាប់ទេដែលខុសគ្នា ដោយសារអំពើប្រល័យពូជសាសន៍អនុវត្តចំពោះក្រុមជាតិសាសន៍ ឬជាតិពន្ធុ តែមិនអនុវត្តចំពោះក្រុមនយោបាយ ឬសេដ្ឋកិច្ចទេ។

47. មេធាវីការពារក្តីយល់ស្របជាមួយសហព្រះរាជអាជ្ញាដែលថា ការបំបែកកិច្ចដំណើរការនីតិវិធីមិនគួរអនុវត្តចំពោះលក្ខណៈសម្បត្តិតាមផ្លូវច្បាប់នៃអង្គហេតុនោះទេ[85]។ ហេតុនេះ បើវិនិច្ឆ័យទៅលើបទចោទនៃអំពើប្រល័យពូជសាសន៍នោះ អង្គជំនុំជម្រះក៏នឹងត្រូវពិចារណាទៅលើការដឹង និងចេតនារបស់ជនជាប់ចោទដែរ ពាក់ព័ន្ធនឹងរាល់បទឧក្រិដ្ឋទាំងអស់ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តប្រឆាំង

---

83 ឯកសារលេខ **E131/1/13.3**, "ជាតិសាសន៍និយម លទ្ធិម៉ាក្សនិយម ការប្រសិទ្ធិនាម និងអំពើប្រល័យពូជសាសន៍នៅក្នុងសៀវភៅដែលមានចំណងជើង៖ *របប ប៉ុល ពត* ជាស្នាដៃនិពន្ធរបស់លោក Ben Kiernan, ទំព័រ ៣ (ភាសាអង់គ្លេស)។

84 ឯកសារលេខ **E131/1/13.3**, "ជាតិសាសន៍និយម លទ្ធិម៉ាក្សនិយម ការប្រសិទ្ធិនាម និងអំពើប្រល័យពូជសាសន៍នៅក្នុងសៀវភៅដែលមានចំណងជើង៖ *របប ប៉ុល ពត* ជាស្នាដៃនិពន្ធរបស់លោក Ben Kiernan, ទំព័រ ៥ ដល់ ៦ (ភាសាអង់គ្លេស)។

85 សវនាការលើការបំបែកកិច្ចដំណើរការនីតិវិធីរបស់ អ.ជ.ស.ដ (ថ្ងៃទី២), ទំព័រ ១១:៣៧ ដល់ ១៤។

នឹងក្រុមនានាដែលត្រូវបានកំណត់ជាគោលដៅ។ បទឧក្រិដ្ឋទាំងនេះរួមមានយ៉ាងហោចណាស់គឺ អំពើមនុស្សឃាត ការសម្លាប់រង្គាល អំពើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញ[86]។ ប្រសិនបើអនុវត្តចំពោះជនជាតិចាម និងវៀតណាមនោះ សវនាការចំពោះបទចោទទាំងនេះប្រហែលជាសំដៅយ៉ាងសមហេតុផលទៅលើគោលនយោបាយរបស់ពួកខ្មែរក្រហមចំពោះអ្នកខាងក្រៅ ជាចំណុចសំខាន់នៃមនោវិជ្ជារបស់ពួកខ្មែរក្រហម និងគោលនយោបាយរបស់ពួកគេដូចមានរៀបរាប់នៅក្នុងដីកាដំណោះស្រាយ។

48. សម្រាប់សំអាងហេតុទាំងអស់នេះ បទចោទនៃអំពើប្រល័យពូជសាសន៍ក្លាយជាលក្ខណៈជាមូលដ្ឋាន ឬខ្លឹមសារនៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២។ កត្តាផ្សេងៗទៀតដែលសហព្រះរាជអាជ្ញាបានដកស្រង់នៅក្នុងការវាយតម្លៃរបស់ខ្លួនពីភាពជាតំណាងនោះក៏បានគាំទ្រស្រដៀងគ្នាដែរទៅដល់ការបញ្ចូលអំពើប្រល័យពូជសាសន៍ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១៖

ក. *លក្ខណៈនៃបទឧក្រិដ្ឋ និងការចាត់ថ្នាក់នៃបទឧក្រិដ្ឋទាំងនោះ៖* ការបញ្ចូលបទចោទនៃអំពើប្រល័យពូជសាសន៍នឹងធ្វើឱ្យសំណុំរឿង ០០២/០១ កាន់តែមានភាពជាតំណាងចំពោះសំណុំរឿង ០០២ ជាងមុនជារួម ដោយបញ្ចូលប្រភេទទីពីរ ក្នុងចំណោមប្រភេទទាំងបីនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។ ទោះបីមានវិវាទថា តើឧក្រិដ្ឋកម្មប្រឆាំងមនុស្សមានលក្ខណៈធ្ងន់ធ្ងរជាងឧក្រិដ្ឋកម្មសង្គ្រាម ឬយ៉ាងណា[87] ក៏ដោយ ក៏អំពើប្រល័យពូជសាសន៍មានបុព្វសិទ្ធិមួយក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិថាជា "បទឧក្រិដ្ឋនៃឧក្រិដ្ឋកម្មទាំងអស់"[88]។ ហេតុនេះ ការជំនុំជម្រះលើការផ្លាស់ទីលំនៅដោយបង្ខំ និងអំពើប្រល័យពូជសាសន៍តំណាងឱ្យ

---

86 ដីកាដំណោះស្រាយ, កថាខណ្ឌ ១៣៧៣, ១៣៨១, ១៤០២, ១៤០៨។

87 *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kambanda*, សំណុំរឿងលេខ ICTR-97-23-S, "សាលក្រម និងការផ្តន្ទាទោស", ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ១៩៩៨, កថាខណ្ឌ ១៤ ដល់ ១៥ (ភាសាអង់គ្លេស); *ប្រៀបធៀប រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Furundzija*, សំណុំរឿងលេខ IT-95-17/1-A, "សាលក្រម", ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០០, កថាខណ្ឌ ២៤២ ដល់ ២៤៣ (ភាសាអង់គ្លេស) (ដោយពិភាក្សាពីច្បាប់យុត្តិសាស្ត្រដែលមានវិវាទ)។

88 *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Kambanda*, សំណុំរឿងលេខ ICTR-97-23-S, សាលក្រម និងការផ្តន្ទាទោស", ថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ១៩៩៨, កថាខណ្ឌ ១៦ (ភាសាអង់គ្លេស)។

បទឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់ល្អជាង ការជំនុំជម្រះលើការផ្លាស់ទីលំនៅដោយបង្ខំតែមួយ ឬ ការផ្លាស់ទីលំនៅដោយបង្ខំ និងមន្ទីរ ស២១។

ខ. *ជនរងគ្រោះ៖* ដោយពឹងផ្អែកលើរបាយការណ៍ស្តីពីរបាយប្រជាជនរបស់ Ewa Tabeau ដីកាដំណោះស្រាយបានសន្និដ្ឋានថា មានជនជាតិចាមចំនួន ៩០.០០០ នាក់ និង ជនជាតិវៀតណាមចំនួន ២០.០០០ នាក់ត្រូវបានសម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងបានដកស្រង់តួលេខទាំងពីរនេះថាជាភស្តុតាងនៃចេតនាប្រល័យពូជសាសន៍[89]។ នៅក្នុងដីកាដំណោះស្រាយពុំមានទីតាំងឧក្រិដ្ឋកម្មណាមួយបង្ហាញពីមូលហេតុដែលនាំឲ្យមានមនុស្សស្លាប់ជាច្រើនទេ រួមទាំងមន្ទីរ ស២១[90] ឬ ការផ្លាស់ទីលំនៅដោយបង្ខំ[91]។ ក្រៅពីការផ្លាស់ទីលំនៅដោយបង្ខំ ពុំមានអង្គហេតុណាមួយត្រូវបានចោទប្រកាន់ថាមានផលប៉ះពាល់ទៅដល់ជនរងគ្រោះជាច្រើនបែបនេះទេ។ អង្គជំនុំជម្រះសាលាដំបូងផ្តល់ទម្ងន់តែមួយទៅលើចំនួនជនរងគ្រោះដែលត្រូវបានចោទប្រកាន់ថាត្រូវទទួលរងផលប៉ះពាល់ពីការផ្លាស់ទីលំនៅដោយបង្ខំ[92] ហើយហេតុនេះគេត្រូវពិចារណាទៅលើកត្តាដូចគ្នានេះពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍។ ការណ៍ដែលអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានធ្វើបែបនេះ គឺជាការបំពានឆន្ទានុសិទ្ធិ។

ជនរងគ្រោះពីអំពើប្រល័យពូជសាសន៍គឺតំណាងឲ្យជនរងគ្រោះទាំងមូល។ បើតាមលក្ខណៈរបស់វា អំពើប្រល័យពូជសាសន៍ចាត់ទុកជាគោលដៅយ៉ាងរើសអើងនូវក្រុមមួយ ហើយហេតុនេះ វាបានប៉ះពាល់គ្រប់ផ្នែកទាំងអស់ក្នុងចំណោមប្រជាជន។ ដីកាដំណោះស្រាយបានចោទប្រកាន់ថា ជនជាតិវៀតណាមគ្រប់រូបដែលរស់នៅប្រទេសកម្ពុជានៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ

---

89 ដីកាដំណោះស្រាយ, កថាខណ្ឌ ៧៩៧, ៧៩២, ១៣៩២, ១៣៤៩; ឯកសារលេខ **D140/1/1**, "ជនរងគ្រោះនៃរបបខ្មែរក្រហមពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩៖ ការវាយតម្លៃស៊ីជម្រៅលើការប៉ាន់ប្រមាណសំខាន់ៗ" ("របាយការណ៍របស់ Tabeau"), ទំព័រ ៤៩ ដល់ ៥០ (ភាសាអង់គ្លេស)។

90 ដីកាដំណោះស្រាយ, កថាខណ្ឌ ៤២៣។

91 ដីកាដំណោះស្រាយ, កថាខណ្ឌ ២៤០; ឯកសារលេខ **E1/189.1**, "ប្រតិចារឹកនៃកិច្ចដំណើរការសវនាការ", ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ២០១៣, ទំព័រ ៣៩:១៧ ដល់ ៤០:៤ (ភាសាអង់គ្លេស)។

92 សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១១២, ១១៦។

១៩៧៥ និងចំនួន ៣៦% នៃជនជាតិចាមត្រូវបានសម្លាប់[93]។ បើតាមលោក អ៊ីសា ឧស្មាន "ជនជាតិចាមត្រូវបានសម្លាប់នៅគ្រប់មូលដ្ឋានទូទាំងប្រទេសកម្ពុជា"[94] រួមមាននៅក្រុងភ្នំពេញ[95] ខេត្តពោធិ៍សាត់[96] ខេត្តកំពង់ចាម[97] ខេត្តកំពត[98] ខេត្តកំពង់ធំ[99] ខេត្តព្រៃវែង[100] និងខេត្តកណ្តាល[101] ក្នុងចំណោមកន្លែងផ្សេងៗទៀត។ ពួកគេជាមន្ត្រីរដ្ឋាភិបាល លន់ នល់ សិស្ស អ្នកនេសាទ អ្នកបកប្រែភាសា អ្នកតំណាងសាសនា និងសាស្ត្រាចារ្យ[102]។ អង្គជំនុំជម្រះសាលាដំបូងបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ដោយសម្រេចថា ការចោទប្រកាន់នានាពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ត្រូវបានកម្រិតត្រឹម "ការសម្លាប់ជនជាតិវៀតណាម និងចាម" ដោយមិនបានពិចារណាផងទេទៅលើទំហំទូលំទូលាយនៃជនរងគ្រោះដែលទទួលរងផលប៉ះពាល់[103]។

គ. *វិសាលភាពភូមិសាស្ត្រ៖* ដីកាដំណោះស្រាយបានចោទប្រកាន់ថា ការសម្លាប់ជនស៊ីវិលវៀតណាមគឺ "ត្រូវបានរៀបចំជាគោលនយោបាយជាតិ"[104]។ ជនជាតិចាម និងវៀតណាមត្រូវបានអះអាងថាត្រូវគេសម្លាប់នៅគ្រប់ភូមិភាគ និងតំបន់ស្វ័យតទាំងអស់នៃរបបកម្ពុជាប្រជាធិបតេយ្យ គ្របដណ្តប់ទៅលើទីកន្លែងនានាក្នុងខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តមណ្ឌលគិរី ខេត្តកំពត ខេត្តតាកែវ ខេត្តក្រចេះ ខេត្តកោះកុង ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តរតនគិរី ខេត្តកំពង់

---

93 ដីកាដំណោះស្រាយ, កថាខណ្ឌ ៧៩៧, ៧៩២។

94 ឯកសារលេខ **E3/1822**, "Oukoubah: យុត្តិធម៌សម្រាប់ជនជាតិចាមក្រោមរបបកម្ពុជាប្រជាធិបតេយ្យ", ឆ្នាំ ២០០២ ('ឧស្មាន'), ទំព័រ ៦ (ភាសាអង់គ្លេស)។

95 ឧស្មាន, ទំព័រ ១១, ១២, ២១, ៣១, ៤៥, ៥០, ៥៣, ៦៨ (ភាសាអង់គ្លេស)។

96 ឧស្មាន, ទំព័រ ១៩ (ភាសាអង់គ្លេស)។

97 ឧស្មាន, ទំព័រ ៤៦, ១២០ ដល់ ១២១ (ភាសាអង់គ្លេស)។

98 ឧស្មាន, ទំព័រ ៧២, ៧៥ (ភាសាអង់គ្លេស)។

99 ឧស្មាន, ទំព័រ ១២០ ដល់ ១២១ (ភាសាអង់គ្លេស)។

100 ឧស្មាន, ទំព័រ ១២២ ដល់ ១២៤ (ភាសាអង់គ្លេស)។

101 ឧស្មាន, ទំព័រ ១២០ ដល់ ១២៤ (ភាសាអង់គ្លេស)។

102 ឧស្មាន, ទំព័រ ៨, ១២, ៦៦, ៦៩, ៧៤, ១១៩, ១២២ ដល់ ១២៣ (ភាសាអង់គ្លេស)។

103 សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១១៣។

104 ដីកាដំណោះស្រាយ, កថាខណ្ឌ ៨០២។.

ចាម ខេត្តកំពង់ធំ និង ខេត្តសៀមរាប[105]។ អង្គជំនុំជម្រះសាលាដំបូងសំអាងលើភាពជាតំណាងភូមិសាស្ត្រនៃបទចោទពីការផ្លាស់ទីលំនៅដោយបង្ខំ តែពុំបានចាត់ទុកថាវាមានទំនាក់ទំនងនឹងអំពើប្រល័យពូជសាសន៍ទេ ហេតុនេះវាជាការបំពានឆន្ទានុសិទ្ធិរបស់ខ្លួន។

ឃ. *វិសាលភាពពេលវេលា៖* គោលនយោបាយរបស់ពួកខ្មែរក្រហមពាក់ព័ន្ធនឹងជនជាតិចាម និងវៀតណាមត្រូវបានអះអាងថាបានគ្របដណ្តប់ទៅលើវិសាលភាពពេលវេលានៃរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ដោយចាប់ផ្តើមពីមុនឆ្នាំ១៩៧៥ និងបន្តរហូតដល់ថ្ងៃទី6 ខែមករា ឆ្នាំ១៩៧៩[106]។ ហេតុនេះវាមានភាពជាតំណាងនៃពេលវេលាជាងការផ្លាស់ទីលំនៅដោយបង្ខំទាំងក្នុងដំណាក់កាលទី១ និងទី២ ទៅទៀត ដែលបញ្ចប់នៅឆ្នាំ១៩៧៧[107] ឬមន្ទីរ ស២១ ដែល "ដំណើរការពេញលេញនៅខែតុលា ឆ្នាំ១៩៧៥"[108]។

49. សម្រាប់សំអាងហេតុទាំងនេះ អង្គជំនុំជម្រះតុលាការកំពូលគួរសន្និដ្ឋានថា បទចោទនៃអំពើប្រល័យពូជសាសន៍មានសារៈសំខាន់ដល់ការជំនុំជម្រះនានាក្នុងដីកាដំណោះស្រាយនៃសំណុំរឿង ០០២ និងប្រសិនបើអង្គជំនុំជម្រះសម្រេចមិនទុកជាមោឃៈនូវសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីទេ អង្គជំនុំជម្រះគួរណែនាំទៅអង្គជំនុំជម្រះសាលាដំបូងឲ្យបញ្ចូលបទចោទទាំងនោះទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១។

<u>iii – សំណុំរឿង ០០២/០១ ត្រូវបញ្ចូលសហករណ៍ និងការដ្ឋាន</u>

50. សម្រាប់សំអាងហេតុនានាដែលបានលើកឡើងរួចមកហើយ[109] សវនាការដែលមានភាពជាតំណាងសមរម្យចំពោះដីកាដំណោះស្រាយនៃសំណុំរឿង ០០២ ត្រូវបញ្ចូលការវាយតម្លៃពេញលេញមួយពី

---

105 ដីកាដំណោះស្រាយ, កថាខណ្ឌ ៧៩៧ ដល់ ៨០៣។

106 ដីកាដំណោះស្រាយ, កថាខណ្ឌ ៧៥៣ ដល់ ៧៧០, ៧៩២ ដល់ ៨០៤។

107 ដីកាដំណោះស្រាយ, កថាខណ្ឌ ២៦២។

108 ដីកាដំណោះស្រាយ, កថាខណ្ឌ ៤១៦។

109 *សូមមើល* កថាខណ្ឌ ១៣ ដល់ ១៧ *ខាងលើ*។

ចេតនា និងគោលដៅរបស់បដិវត្តន៍ខ្មែរក្រហម។ ពាក់ព័ន្ធនឹងអង្គហេតុនានាដែលមានរៀបរាប់ក្នុងដីកាដំណោះស្រាយនោះ ការវាយតម្លៃនេះនឹងតម្រូវឲ្យបញ្ចូលបទឧក្រិដ្ឋនានាដែលត្រូវបានប្រព្រឹត្តនៅតាមសហករណ៍ និងការដ្ឋាន។ ការពិសោធន៍ដែលសហព្រះរាជអាជ្ញាបានសំអាង បានគាំទ្រដល់សេចក្តីសន្និដ្ឋានបែបនោះ។

51. *លក្ខណៈជាមូលដ្ឋាន ឬខ្លឹមសារនៃដីកាដំណោះស្រាយក្នុងសំណុំរឿង៖* ដីកាដំណោះស្រាយបានចោទប្រកាន់ថា ប្រសិទ្ធភាពរួមគ្នានៃគោលនយោបាយទាំង ៥ របស់របបកម្ពុជាប្រជាធិបតេយ្យគឺ "ការធ្វើសមូហភាវូបនីយកម្មសង្គមលើគ្រប់វិស័យទាំងអស់"[110]។ សមូហភាវូបនីយកម្មសង្គមនោះត្រូវបានចោទប្រកាន់ថា ពាក់ព័ន្ធនឹងការគាបសង្កត់សេរីភាពផ្នែកសេដ្ឋកិច្ច និង "ការបង្ខំឲ្យមនុស្សទាំងអស់ត្រូវរស់នៅរួមជាលក្ខណៈទូទៅ"[111]។ ហេតុនេះ ជីវិតនៅក្នុងអង្គភាពរួមដូចជា សហករណ៍ និង ការដ្ឋាននោះ ត្រូវបានចោទប្រកាន់ថា ជាបទពិសោធន៍ប្រចាំថ្ងៃនៃប្រជាជនកម្ពុជាដែលមានចំនួនដ៏ច្រើនលើសលប់។

52. ដីកា*ដំណោះ*ស្រាយចោទប្រកាន់ថា តាមរយៈសហករណ៍ និងការដ្ឋានទាំងនេះ នួន ជា បានដាក់ឲ្យប្រជាជនកម្ពុជារាប់លាននាក់ទៅក្នុងស្ថានភាព "បែបអមនុស្សធម៌" ដែលបណ្តាលឲ្យមានព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់សុខភាព និងជាញឹកញយបណ្តាលឲ្យស្លាប់[112]។ ប្រសិនបើអំពើប្រល័យពូជសាសន៍ជាបទឧក្រិដ្ឋដែលធ្ងន់ធ្ងរជាងគេដែល នួន ជា ត្រូវបានចោទប្រកាន់នោះ រាល់បទឧក្រិដ្ឋនានាដែលត្រូវបានប្រព្រឹត្តនៅតាមសហករណ៍គឺជាបទឧក្រិដ្ឋដែលមានភាពទូលំទូលាយបំផុត និងជាបទឧក្រិដ្ឋដែលត្រូវបានប៉ះពាល់យ៉ាងពេញលេញជាងគេដល់ប្រជាជនកម្ពុជាសាមញ្ញ។ គឺពិតជាដើម្បីប្រជាជនកម្ពុជាសាមញ្ញទាំងនេះហើយដែល នួន ជា បានចូលរួមក្នុងបក្សកុម្មុយនីស្តកម្ពុជា និងបានដឹកនាំបង្កើត

---

110 ដីកាដំណោះស្រាយ, កថាខណ្ឌ ១៥៨។

111 ដីកាដំណោះស្រាយ, កថាខណ្ឌ ១៥៨។

112 ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤៣៤, ១៤៣៧។

បដិវត្តន៍សង្គមនិយមមួយឡើង។ គាត់មានសិទ្ធិជំទាស់នូវការចោទប្រកាន់ដែលថា គាត់មានចេតនាបណ្ដាលឲ្យពួកគេទទួលរងនូវព្យសនកម្មយ៉ាងធ្ងន់ធ្ងរបែបនេះ។

53. *លក្ខណៈ និងការចាត់ថ្នាក់នៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់៖* ស្ទើរតែគ្រប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទាំងអស់ដែល នួន ជា ត្រូវបានចោទប្រកាន់ រួមមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឲ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងគ្រប់សហករណ៍ និងការដ្ឋានទាំងអស់នៅក្នុងដីកាដំណោះស្រាយ[113]។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលនៅសេសសល់ដូចជា ការធ្វើទារុណកម្ម និងការដាក់ក្នុងមន្ទីរឃុំឃាំង ត្រូវបានចោទប្រកាន់ថាមានទំនាក់ទំនងទៅនឹងសហករណ៍ត្រាំកក់[114]។

54. *វិសាលភាពភូមិសាស្ត្រ និងពេលវេលា៖* សហករណ៍ និងការដ្ឋានត្រូវបានចោទប្រកាន់ថា “ត្រូវបានរៀបចំឡើងនៅទូទាំងប្រទេសកម្ពុជា ចាប់តាំងពីមុនឆ្នាំ១៩៧៥ ដោយបក្សកុម្មុយនីស្តកម្ពុជាមកម្ល៉េះពោលគឺ ដំណាក់កាលដំបូងនៃការត្រួតត្រារបស់បក្សកុម្មុយនីស្តកម្ពុជាលើដែនដីមួយចំនួនរបស់ប្រទេស [...] រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩” ហើយហេតុនេះ វាគ្របដណ្ដប់លើវិសាលភាពភូមិសាស្ត្រ និងពេលវេលាទាំងមូលនៃដីកាដំណោះស្រាយ[115]។ យ៉ាងហោចណាស់មានសហករណ៍មួយ និងការដ្ឋានមួយ ដែលត្រូវបានចោទប្រកាន់ថាបានដំណើរការពេញមួយរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល[116]។

55. *ជនរងគ្រោះ៖* ដីកាដំណោះស្រាយមិនបានបញ្ជាក់ច្បាស់ពីចំនួនប្រជាជនដែលត្រូវបានទទួលរងផលប៉ះពាល់ដោយសារសហករណ៍ និងការដ្ឋានទេ តែពាក់ព័ន្ធនឹងវិសាលភាពភូមិសាស្ត្រ និងពេលវេលា

---

[113] ដីកាដំណោះស្រាយ, កថាខណ្ឌ ១៣៧៣, ១៣៨១, ១៨៩១, ១៩១៦, ១៩៣៤។

[114] ដីកាដំណោះស្រាយ, កថាខណ្ឌ ១៩០២, ១៩០៨។

[115] ដីកាដំណោះស្រាយ, កថាខណ្ឌ ១៦៨។

[116] ដីកាដំណោះស្រាយ, កថាខណ្ឌ ៣០៣, ៣៧០។

នោះ ទំនងជាថា ត្រូវបានពិចារណាថាមានចំនួនច្រើនណាស់។ សហករណ៍ត្រូវបានចោទប្រកាន់ថា បានប៉ះពាល់ដល់សង្គមកម្ពុជាគ្រប់វិស័យទូលំទូលាយជាងគេ រួមមាន "ប្រជាជនមូលដ្ឋាន" "ប្រជាជនថ្មី" និងប្រជាជនដែលត្រូវបានជម្លៀសទៅទីនោះ ពីទីកន្លែងភូមិសាស្ត្រនានានៅទូទាំងប្រទេស[117]។

## ឃ. អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសឆ្គងដោយពុំបានបញ្ចូលមន្ទីរ សង២១ ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ទេ

56. ខុសពីមេធាវីការពារក្តី នួន ជា សហព្រះរាជអាជ្ញាបានទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងកំរិតវិសាលភាពនៃសំណុំរឿង ០០២/០១ បានត្រឹមត្រូវ មកត្រឹមតែការចោទប្រកាន់លើអង្គហេតុដែលមួយចំនួនវិញ។ ក្នុងករណីដែលមានលក្ខណៈធំធេង និង ស្មុគស្មាញដូចសំណុំរឿង ០០២ គំរូតូចមួយនៃបទចោទប្រកាន់ពុំអាចតំណាង "សមហេតុផល" ទៅនឹងដីកាដំណោះស្រាយទាំងមូលបានទេ។ ការពុំមានការណែនាំច្បាស់លាស់ដើម្បីសម្រាប់ពីចំណុចជាក់លាក់ដែលសំណុំរឿង ០០២/០១ មានភាពជាតំណាងគ្រប់គ្រាន់នោះ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងចំណុចនេះ ចាំបាច់តម្រូវឲ្យអនុវត្តនូវឆន្ទានុសិទ្ធិចម្បង[118]។ ហេតុនេះ អង្គជំនុំជម្រះនេះគួរគោរពដល់ឆន្ទានុសិទ្ធិនេះ។

<u>i – មន្ទីរ សង២១ មិនតំណាងជាពិសេសឲ្យដីកាដំណោះស្រាយនៃសំណុំរឿង ០០២/០១ ទេ</u>

57. ពុំមានចំណុចណាមួយនៃការពិសោធន៍របស់សហព្រះរាជអាជ្ញា[119] គាំទ្រដល់យោបល់របស់ខ្លួនដែលថា មន្ទីរ សង២១ តំណាងជាពិសេសដល់បទចោទនានាប្រឆាំងនឹងជនជាប់ចោទ។ មន្ទីរ សង២១ មានភាពជា

[117] ដីកាដំណោះស្រាយ, កថាខណ្ឌ ១៦១ "គោលដៅមួយក្នុងចំណោមគោលដៅទាំងអស់នៃការផ្លាស់ទីលំនៅប្រជាជន គឺដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃកម្លាំងពលកម្មសំរាប់សហករណ៍ និងការដ្ឋានទាំងឡាយ"។

[118] សេចក្តីសម្រេចរបស់ អ.ជ.ត.ក លើការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៣៥ (ដោយបញ្ជាក់ពីឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការអនុវត្តវិធាន ៨៩*ស្ទួនពីរ*)។

[119] បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៣០ ដល់ ៣៤ (ដោយពណ៌នាពីកត្តានានាដែលពាក់ព័ន្ធ)។

តំណាងតិចជាងការជម្លៀសដោយបង្ខំ ទាំងទៅលើវិសាលភាពនៃជនរងគ្រោះដែលបានអះអាង និងតំបន់ភូមិសាស្ត្រដែលគ្របដណ្តប់។ មន្ទីរ ស២១ ពុំមានភាពជាតំណាងច្រើនជាងទីតាំងឧក្រិដ្ឋកម្មមួយក្នុងចំណោមទីតាំងជាច្រើនទៀតពាក់ព័ន្ធនឹងវិសាលភាពលើពេលវេលា និងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់។ ពាក់ព័ន្ធនឹងខ្លឹមសារ ឬលក្ខណៈជាមូលដ្ឋាននៃសំណុំរឿងវិញ មន្ទីរ ស២១ នឹងនាំឲ្យមានប្រែប្រួលនូវលក្ខណៈសម្បត្តិជាវិជ្ជមាននៃសំណុំរឿង ០០២/០១ ពាក់ព័ន្ធនឹងសំណុំរឿង ០០២ ទាំងមូល។

58. *វិសាលភាពនៃជនរងគ្រោះដែលបានអះអាង៖* មន្ទីរ ស២១ បណ្តាលឲ្យមានជនរងគ្រោះប្រហែល ១២.០០០ នាក់ និង ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១២៨ នាក់[120] និងនៅក្នុងទិដ្ឋភាពទាំងពីរគឺប្រហាក់ប្រហែលទៅនឹងបទឧក្រិដ្ឋ និងទីតាំងឧក្រិដ្ឋកម្មផ្សេងទៀតដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ[121]។ ក្នុងចំណោមជនរងគ្រោះនៅមន្ទីរ ស២១ ដីកាដំណោះស្រាយបានអះអាងថា មានចំនួន ៨១% គឺជាសមាជិក ប.ក.ក ឬ កងទ័ពបដិវត្តន៍កម្ពុជា[122]។ ចំនួន ១២% ទៀតត្រូវបានយកទៅឃុំឃាំង ដោយសារមូលហេតុមិនច្បាស់លាស់ ឬ ដោយសារពួកគេមានទំនាក់ទំនងគ្រួសារជាមួយអ្នកជាប់ឃុំឃាំងផ្សេងទៀត[123]។ ហេតុការណ៍តែមួយដែលថា យូរៗម្តងមានប្រជាជនពីក្រុមជាតិពន្ធុផ្សេងៗទៀតក៏ត្រូវបានឃុំឃាំងផងដែរនោះ មិនបានផ្លាស់ប្តូរលក្ខណៈសម្បត្តិរបស់មន្ទីរសន្តិសុខនេះទេ។ វាមិនអាចធ្វើឲ្យមន្ទីរ ស២១ មានភាពជាតំណាងដល់ជនរងគ្រោះជាងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ថាបានប៉ះពាល់ដល់ប្រជាជនកម្ពុជាចំនួនជិតពាក់កណ្តាលនោះទេ។

---

[120] ដីកាដំណោះស្រាយ, កថាខណ្ឌ ៤២៣, ៤៧៥។

[121] *សូមមើលឧទាហរណ៍,* ដីកាដំណោះស្រាយ, កថាខណ្ឌ ៣៥០ (ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩៩ នាក់ ពាក់ព័ន្ធនឹងការដ្ឋានទំនប់ត្រពាំងថ្ម); កថាខណ្ឌ ៧៤៤ (ដើមបណ្តឹងរដ្ឋរប្បវេណីចំនួន ៨៧ នាក់ ពាក់ព័ន្ធនឹងប្រព្រឹត្តកម្មលើពុទ្ធសាសនិក), កថាខណ្ឌ ៨៦១ (ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៦៤ នាក់ ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ), កថាខណ្ឌ ៣០១ (ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២១៩ នាក់ ពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំក្នុងដំណាក់កាលទី៣)។

[122] ដីកាដំណោះស្រាយ, កថាខណ្ឌ ៤២៤ ដល់ ៤២៥។

[123] ដីកាដំណោះស្រាយ, កថាខណ្ឌ ៤៣២។

59. *វិសាលភាពភូមិសាស្ត្រ៖* វាមិនត្រូវបានជំទាស់ថា *ស្ថានភាព (situs)* នៃបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅមន្ទីរ ស២១ គឺកម្រិតតែនៅក្រុងភ្នំពេញប៉ុណ្ណោះនោះទេ។ ទោះបីសហព្រះរាជអាជ្ញាបានអះអាងថា មន្ទីរ ស២១ មានភាពចំរុះគ្នាទៅតាមភូមិសាស្ត្រ ដោយសារអ្នកជាប់ឃុំឃាំងត្រូវបានអះអាងថា មានប្រភពមកពីគ្រប់ទីកន្លែងនៃផ្ទៃប្រទេស[124] ការពិសោធន៍របស់ពួកគេផ្តោតតែទៅលើទីកន្លែងប្រភពដើមរបស់ជនរងគ្រោះ តែមិនផ្តោតលើ “ទីកន្លែងដែល [បទឧក្រិដ្ឋ] ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត” នោះទេ[125]។ ក្នុងករណីនេះ ការណ៍ដែលថា បទឧក្រិដ្ឋនៅមន្ទីរ ស២១ បានកើតឡើងតែនៅលើទីតាំងភូមិសាស្ត្រតែមួយ គឺជាសារៈសំខាន់ពិសេស ដោយសារវាមានទំនាក់ទំនង និងឆ្លុះបញ្ចាំងវិធីផ្សេងៗទៀតដែល មន្ទីរ ស២១ មិនតំណាងឲ្យដីកាដំណោះស្រាយជារួមទេ[126]។

60. *វិសាលភាពលើពេលវេលា និងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់៖* អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា បទឧក្រិដ្ឋដែលខ្លួនបានបញ្ចូលក្នុងសំណុំរឿង ០០២/០១ មិនបានគ្របដណ្តប់ទៅលើរយៈពេល ៣ ឆ្នាំ ៨ ខែពេញ នៃរបបកម្ពុជាប្រជាធិបតេយ្យ ឬបទឧក្រិដ្ឋទាំងអស់ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយទេ[127]។ អង្គជំនុំជម្រះបានផ្តល់ទម្ងន់ដល់កត្តាទាំងនេះជាងវិសាលភាពនៃជនរងគ្រោះដែលបានអះអាង និងទីកន្លែងនៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ និងផ្តល់ទម្ងន់ដល់កត្តាពីរចុងក្រោយខ្លាំងជាង[128]។ អង្គជំនុំជម្រះមិនបានព្រងើយកន្តើយលើសេចក្តីពិចារណានានាដែលពាក់ព័ន្ធទេ ហើយក៏មានសិទ្ធិក្នុងការអនុវត្តន៍ឆន្ទានុសិទ្ធរបស់ខ្លួនក្នុងការពិចារណាលើកត្តាទាំងនោះដែរ។

---

124 បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៣៨។

125 បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៣១។

126 *សូមមើល* កថាខណ្ឌ ៦២ ដល់ ៧១, *ខាងក្រោម*។

127 សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១១១, ១១៣, ១១៥។

128 សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១១៨។

61. អង្គជំនុំជម្រះសាលាដំបូងយល់បានត្រឹមត្រូវនៅពេលខ្លួនសង្កេតឃើញថា ពុំមានវិធីជាមូលដ្ឋានដើម្បីបំបែកទិដ្ឋភាពទាំងនេះរវាងមន្ទីរ ស២១ និង បទឧក្រិដ្ឋផ្សេងៗទៀតដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនោះទេ[129]។ បទឧក្រិដ្ឋជាច្រើន និងទីតាំងឧក្រិដ្ឋកម្មនានាត្រូវបានចោទប្រកាន់បានកើតឡើងនៅគ្រប់ទីកន្លែង ឬកន្លែងភាគច្រើននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[130]។ រាល់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនីមួយៗដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានចោទប្រកាន់ថាបានកើតឡើងនៅតាមមន្ទីរសន្តិសុខ ទីកន្លែងសម្លាប់មនុស្ស សហករណ៍ និង ការដ្ឋានជាច្រើន[131]។ ទោះបីមានទីតាំងឧក្រិដ្ឋកម្មតិចតួចមានទំនាក់ទំនងនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរដែលត្រូវបានចោទប្រកាន់ក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើអង្គហេតុនោះ បានកត់សម្គាល់ទៅលើការរំលោភបំពានយ៉ាងធ្ងន់ធ្ងរដែលត្រូវផ្តោតការយកចិត្តទុកដាក់យ៉ាងចង្អៀតទាំងលើអង្គហេតុ និងអង្គច្បាប់ នៅក្នុងដីកាដំណោះស្រាយ និងបានសន្និដ្ឋានថា វាពុំមានភាពជាតំណាងសំខាន់ដល់សវនាការនៃសំណុំរឿង ០០២/០១ ដែលត្រូវបញ្ចូលចំណុចទាំងនោះទេ[132]។ សេចក្តីសន្និដ្ឋានទាំងនោះក៏ត្រូវបានធ្វើឡើងទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួនដែរ។

62. *ខ្លឹមសារជាមូលដ្ឋាន ឬលក្ខណៈនៃរឿងក្តី៖* ដូចដែលមេធាវីការពារក្តីបានលើកជាទឡ្ហីករណ៍នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងរួចមកហើយគឺថា ទស្សនៈរបស់សហព្រះរាជអាជ្ញាដែលថា មន្ទីរ ស២១ គឺជាទីតាំងឧក្រិដ្ឋកម្មដែលមានភាពជាតំណាងនៅក្នុងដីកាដំណោះស្រាយ គឺជាការបកស្រាយ

---

129 សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១២២ (ការដាក់បន្ថែមមន្ទីរ ស២១ អាចធ្វើឱ្យសំណុំរឿង ០០២/០១ មានភាពជាតំណាង "ច្រើនជាងមុន" ក៏ដោយ "ក្នុងន័យថា ការបន្ថែមទីតាំងឧក្រិដ្ឋកម្ម*ណាមួយ*នឹងជួយបន្ថែមភាពជាតំណាងនេះ")។

130 ក្នុងចំណោមទីកន្លែងដទៃទៀត ទីកន្លែងទាំងនេះរួមមានសហករណ៍ត្រាំកក់ ការដ្ឋានស្រែអំបិល ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខកោះខ្យង និង មន្ទីរសន្តិសុខភ្នំក្រោល និង រាល់បទចោទទាំងអស់ដែលពាក់ព័ន្ធនឹងការប្រព្រឹត្តទៅលើក្រុមមនុស្សជាគោលដៅ។ ស្ទើរតែគ្រប់មន្ទីរសន្តិសុខទាំងអស់នៅក្នុងដីកាដំណោះស្រាយត្រូវបានដំណើរការក្នុងរយៈពេល ២ ឆ្នាំចុងក្រោយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយហេតុនេះវាគ្របដណ្តប់លើវិសាលភាពលើពេលវេលាពេញលេញនៃរបបនេះទាំងមូលរួមជាមួយនឹងការផ្លាស់ប្តូរទីលំនៅប្រជាជនក្នុងដំណាក់កាលទី១ និងទី២ ផងដែរ។

131 ដីកាដំណោះស្រាយ, កថាខណ្ឌ ១៣៧៣ ដល់ ១៤៧៨។

132 សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១១៣។

ខុសការពិតទាំងស្រុង[133]។ មន្ទីរ ស២១ ពុំមានទំនាក់ទំនងទាល់តែសោះជាមួយនឹងខ្លឹមសារសំខាន់របស់រឿងក្តីនេះ គឺការខិតខំរបស់ពួកខ្មែរក្រហមក្នុងការអនុវត្តន៍បដិវត្តន៍សង្គមនិយមតាមរយៈជំហានមហាលោតផ្លោះ។ វាជាការបង្ហាញជាពិសេសនិងផ្សេងពីគ្នានៃខ្លឹមសារទីពីររបស់រឿងក្តី គឺការខិតខំប្រឹងប្រែងការពារបដិវត្តន៍ប្រឆាំងនឹងខ្មាំងខាងក្នុង និងខាងក្រៅ។ សវនាការទៅលើការជម្លៀសដោយបង្ខំ និង មន្ទីរ ស២១ តែមួយនឹងមិនតំណាងបទឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ និង ព្រឹត្តិការណ៍នានាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។

63. ដីកាដំណោះស្រាយបានចោទប្រកាន់ថា គោលបំណងរួមជាមូលដ្ឋានរបស់សហឧក្រិដ្ឋកម្មគឺ៖

> ឲ្យសម្រេចបាននូវបដិវត្តន៍សង្គមនិយមឆាប់រហ័សនៅកម្ពុជាតាម "ជំហានមហាលោតផ្លោះ" និងការការពារប្រទេសប្រឆាំងទៅនឹងសត្រូវទាំងខាងក្នុង និងខាងក្រៅ តាមគ្រប់មធ្យោបាយចាំបាច់[134]។

សហព្រះរាជអាជ្ញាបានអនុម័តយកសេចក្តីថ្លែងការណ៍នេះធ្វើជាខ្លឹមសាររបស់របបកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងពេលសវនាការស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[135]។ នាពេលនេះ ពួកគេមានបង្កើតជាថ្មីនូវខ្លឹមសារជាមូលដ្ឋាន ក្នុងការខិតខំប្រឹងប្រែងយ៉ាងមានតម្លាភាព ដើម្បីតម្រឹមទៅតាមមន្ទីរ ស២១ តាមតែអាចធ្វើទៅបាន៖ "បទចោទថា ប្រជាជនកម្ពុជារាប់សែននាក់ត្រូវបានឃុំឃាំងដោយខុសច្បាប់ រងការធ្វើទារុណកម្ម និងត្រូវបានសម្លាប់នៅតាមបណ្តាញមន្ទីរសន្តិសុខ ដោយអនុលោមតាមគោលនយោបាយ និងសេចក្តីសម្រេចរបស់ថ្នាក់ដឹកនាំនៃប.ក.ក"[136]។

---

133 សវនាការលើការបំបែកកិច្ចដំណើរការនីតិវិធីរបស់ អ.ជ.ស.ដ (ថ្ងៃទី២), ទំព័រ ១២:២២ ដល់ ១៤:២៥ (ភាសាអង់គ្លេស)។

134 ដីកាដំណោះស្រាយ, កថាខណ្ឌ ១៥២៤។

135 សវនាការលើការបំបែកកិច្ចដំណើរការនីតិវិធីរបស់ អ.ជ.ស.ដ (ថ្ងៃទី២), ទំព័រ ៥៦:២ ដល់ ៧ (ភាសាអង់គ្លេស)។

136 បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៤៥។

64. សូម្បីតែការលើកឡើងពីលទ្ធិសង្គមនិយម បដិវត្តន៍ លទ្ធិកុម្មុយនីស្ត ឬជំហានមហាលោតផ្លោះ ក៏ត្រូវបានដកចេញពីទម្រង់នេះដែរ។ បើតាមការយល់ឃើញរបស់សហព្រះរាជអាជ្ញាគឺថា ដីកាដំណោះស្រាយនឹងពុំមានលក្ខណៈសម្បត្តិខុសគ្នាទេ ដោយសារពួកខ្មែរក្រហមដំណើរការបណ្តាញមន្ទីរសន្តិសុខមួយពុំមែនដើម្បីជាគោលបំណងផ្នែកមនោគមវិជ្ជាដែលបានអះអាងនោះទេ។ តែសហព្រះរាជអាជ្ញានៅតែបានបង្ហាញភស្តុតាងជាច្រើនពាក់ព័ន្ធនឹងមូលដ្ឋានមនោគមវិជ្ជារបស់បដិវត្តន៍ខ្មែរក្រហម[137] និងបានលើកជាទឡ្ហីករណ៍ថា ភស្តុតាងនៃគោលនយោបាយទាំង ៥ របស់របបកម្ពុជាប្រជាធិបតេយ្យ គឺជាការចាំបាច់ដើម្បីយល់បានពីបទឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២/០១[138]។

65. ប្រសិនបើសហព្រះរាជអាជ្ញាបានទទួលស្គាល់នូវ "ខ្លឹមសារជាមូលដ្ឋាន" ដូចគ្នាដែលពួកគេបានបង្កើតនៅក្នុងទឡ្ហីករណ៍របស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនោះ ទំនងជាថា យ៉ាងហោចណាស់ក៏មានបទចោទផ្នែកព្រហ្មទណ្ឌជាច្រើនដែលត្រូវបានចោទប្រកាន់ ទៅតាមកម្មវត្ថុនៃបដិវត្តន៍សង្គមនិយម រួមមាន បទចោទនានាដែលពាក់ព័ន្ធនឹងសហករណ៍ ការដ្ឋាន និងការរៀបចំអាពាហ៍ពិពាហ៍មានសារៈសំខាន់ដូចមន្ទីរ ស២១ ដែរ។

---

[137] *សូមមើលឧទាហរណ៍*, ឯកសារលេខ **E9/31.2**, "ឧបសម្ព័ន្ធ ២៖ ការបោះពុម្ពផ្សាយ និង សេចក្តីណែនាំរបស់ ប.ក.ក", ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ (ដោយស្នើសុំឱ្យទទួលយកជាភស្តុតាងនូវឯកសារ ប.ក.ក ជាច្រើន ក្នុងគោលបំណងបង្ហាញពីមាគ៌ា និង យុទ្ធសាស្ត្ររបស់ ប.ក.ក); ឯកសារលេខ **E1/29.1**, "ប្រតិចារឹកនៃកិច្ចដំណើរការសវនាការ", ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១២ (ក.ស.ព បានដាក់បង្ហាញឯកសារនានាដែលពាក់ព័ន្ធនឹងសារតាប្រវត្តិសាស្ត្ររបស់ ប.ក.ក និងមូលដ្ឋានមនោគមវិជ្ជារបស់បដិវត្តន៍); ឯកសារលេខ **E1/42.1**, "ប្រតិចារឹកនៃកិច្ចដំណើរការសវនាការ", ថ្ងៃទី ១៣ កុម្ភៈ ឆ្នាំ ២០១២ (ស្រដៀងគ្នា)។

[138] ឯកសារលេខ **E96/8**, "សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ និង ប្រតិចារឹក ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ពី ១-១៦" ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២, កថាខណ្ឌ ៣០ ដល់ ៣៤ (ដោយស្នើសុំឱ្យទទួលស្គាល់ភស្តុតាងនៃគោលនយោបាយទាំងអស់របស់របបកម្ពុជាប្រជាធិបតេយ្យថាជាភស្តុតាងបន្ទាប់បន្សំ ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១)។

66. សូម្បីតែនៅក្នុងក្របខណ្ឌចង្អៀតនៃ "មន្ទីរសន្តិសុខ" ក៏មន្ទីរ ស២១ ពុំមែនជាទីតាំងឧក្រិដ្ឋកម្មដែលមានភាពជាតំណាងនោះទេ។ ទោះបីមន្ទីរសន្តិសុខដែលនៅគ្រប់ទីកន្លែងនៃប្រទេសកម្ពុជាត្រូវបានចោទប្រកាន់ថាបានដាក់ទណ្ឌកម្មប្រជាជនជាច្រើនចំពោះបទល្មើសប្រចាំថ្ងៃក៏ដោយ ក៏មន្ទីរ ស២១ ត្រូវបានចោទប្រកាន់ថា គឺជាឧបករណ៍ដ៏សំខាន់សម្រាប់សម្រិតសម្រាំងនយោបាយផ្ទៃក្នុង។ បើតាមដីកាដំណោះស្រាយ មន្ទីរសន្តិសុខស្ថិតនៅតាមតំបន់ភូមិសាស្ត្រជាច្រើន និងបានឃុំឃាំងប្រជាជនមូលដ្ឋាន ប្រជាជនថ្មី កម្មាភិបាល ប.ក.ក និង ជនជាតិភាគតិចលាយចម្រុះគ្នា។ ប្រជាជនត្រូវបានឃុំឃាំងដោយសារមូលហេតុផ្សេងៗគ្នាជាច្រើន រួមមានបទល្មើសតូចតាចដូចជា លួចអាហារជាដើម ដែលគេហៅថា ខុសសីលធម៌ និងបទល្មើសធ្ងន់ធ្ងរដូចជាការក្បត់នយោបាយជាដើម។ ការធ្វើទារុណកម្មត្រូវបានធ្វើឡើងយ៉ាងទូលំទូលាយនៅតាមមន្ទីរសន្តិសុខខ្លះ និងស្ទើរតែគ្មានទេនៅតាមមន្ទីរសន្តិសុខផ្សេងទៀត ការសម្លាប់មនុស្សត្រូវបានធ្វើឡើងជារួមនៅតាមមន្ទីរសន្តិសុខខ្លះ និងយូរៗម្តងនៅតាមមន្ទីរសន្តិសុខផ្សេងៗទៀត[139]។

67. ផ្ទុយទៅវិញ មន្ទីរ ស២១ ត្រូវបានអះអាងថាជា "មន្ទីរនយោបាយផង ជាមន្ទីរកងទ័ពផង"[140]។ ដូចដែលបានកត់សម្គាល់រួចមកហើយគឺថា ភាគច្រើនលើសលប់នៃអ្នកជាប់ឃុំឃាំងគឺជាសមាជិក ប.ក.ក ឬ កងទ័ពបដិវត្តន៍កម្ពុជា[141]។ "មន្ទីរ ស-២១ មានតួនាទីយ៉ាងសំខាន់ក្នុងការយកចម្លើយសារភាពពីអ្នកទោស ដើម្បីវែកមុខបណ្តាញក្បត់ផ្សេងទៀត"[142]។ អ្នកជាប់ឃុំឃាំងស្ទើរតែគ្រប់គ្នានៅ មន្ទីរ ស២១

---

139 *សូមមើលឧទាហរណ៍*, ដីកាដំណោះស្រាយ, កថាខណ្ឌ ៥០០ ដល់ ៥០៣ (សំដៅដល់ ក្រាំងតាចាន់), កថាខណ្ឌ ៥២៣ ដល់ ៥៣០ (សំដៅដល់ កោះខ្យង), កថាខណ្ឌ ៥៤១ ដល់ ៥៤៥ (សំដៅដល់ ព្រៃដំរីស្រុត), កថាខណ្ឌ ៥៥៩ ដល់ ៥៦០ និង ៥៦៣ ដល់ ៥៧០ (សំដៅដល់ វត្តគីរីរម្យ), កថាខណ្ឌ ៥៧៦ និង ៥៨១ ដល់ ៥៨៤ (សំដៅដល់ មន្ទីរសន្តិសុខភូមិភាគឧត្តរ), កថាខណ្ឌ ៥៩៩ និង ៦១០ ដល់ ៦២៣ (សំដៅដល់ អូរកន្សែង), កថាខណ្ឌ ៦៣៤ ដល់ ៦៤២ (សំដៅដល់ ភ្នំក្រោល), កថាខណ្ឌ ៦៥៣ និង ៦៥៨ និង ៦៦៤ (សំដៅដល់ វត្តធ្លក), កថាខណ្ឌ ៦៧៣ ដល់ ៦៨៤ (សំដៅដល់ គោកក្តួច)។

140 ដីកាដំណោះស្រាយ, កថាខណ្ឌ ៤២១។

141 *សូមមើល* កថាខណ្ឌ ៥៨, *ខាងលើ*។

142 ដីកាដំណោះស្រាយ, កថាខណ្ឌ ៤៥៥។

ត្រូវបានអះអាងថាត្រូវគេធ្វើទារុណកម្ម។ លើកលែងតែចំនួនតូចប៉ុណ្ណោះ អ្នកជាប់ឃុំឃាំងគ្រប់គ្នានៅមន្ទីរ ស២១ ត្រូវបានអះអាងថាត្រូវគេយកទៅសម្លាប់[143]។ ពុំមានចំណុចណាមួយក្នុងចំណោមចំណុចទាំងនោះដែល (ពេលនេះ) សហព្រះរាជអាជ្ញាអះអាងថា មន្ទីរ ស២១ ឆ្លុះបញ្ចាំងយ៉ាងសុក្រឹត្យនៃ "បណ្ដាញមន្ទីរសន្តិសុខ" ស្ថិតនៅជាចំណុចសំខាន់នៃសំណុំរឿង ០០២ ទេ។

68. ការសន្និដ្ឋានមួយរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងដំណាក់កាលនេះនៃសវនាការលើសំណុំរឿង ០០២/០១ ដែលថា មន្ទីរ ស២១ តំណាងឲ្យដីកាដំណោះស្រាយទាំងមូល ក៏នឹងរំលោភបំពានយ៉ាងធ្ងន់ធ្ងរដល់សច្ចាធារណ៍និរទោស។ អង្គជំនុំជម្រះនេះធ្លាប់បានពណ៌នាពីមុន (និងយ៉ាងខុសឆ្គង) ពីបទឧក្រិដ្ឋនានាដែល ឌុច ត្រូវបានផ្ដន្ទាទោសនៅមន្ទីរ ស២១ ថាមាន "សភាពធ្ងន់ធ្ងរជាងគេបំផុត" ក្នុងចំណោមតុលាការអន្តរជាតិនានា និង "ពិតជាឧក្រិដ្ឋកម្មមួយនៅក្នុងចំណោមឧក្រិដ្ឋកម្មដ៏អាក្រក់បំផុតនៅក្នុងកំណត់ត្រាប្រវត្តិសាស្ត្ររបស់មនុស្សជាតិ"[144]។ ការសន្និដ្ឋានរបស់លោក Philip Short នៅក្នុងសក្ខីកម្មដែលគាត់ផ្ដល់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែលថា មន្ទីរ ស២១ បានបង្កើតជា "សេនាធិការជាទម្រង់នៃការប្រមូលផ្ដុំ" នៃរបបកម្ពុជាប្រជាធិបតេយ្យជារួមគឺជា "រដ្ឋទាសករ" តែមួយនិងដំបូងគេនៅក្នុងប្រវត្តិសាស្ត្រសម័យទំនើប[145]។ ការសន្និដ្ឋានមួយរបស់អង្គជំនុំជម្រះនេះដែលថា មន្ទីរ ស២១ ក្ដោបទៅលើដីកាដំណោះស្រាយទៅតាមន័យរបស់វានោះនឹងលើកជាយោបល់ថា ការអធិប្បាយទាំងនេះអាចអនុវត្តបានដូចគ្នាទាំងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងបទឧក្រិដ្ឋទាំងអស់ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង ០០២។ យ៉ាងហោចណាស់ ប្រការនេះប្រាកដជានាំឲ្យមានភាពលម្អៀងមិនខាន។

---

143 ដីកាដំណោះស្រាយ, កថាខណ្ឌ ៤៤៨, ៤៥១, ៤៦០ ដល់ ៤៦១។

144 សាលដីកាលើរឿងក្ដី ឌុច, កថាខណ្ឌ ៣៧៦, ៣៨០។

145 ឯកសារលេខ **E1/191.1**, "ប្រតិចារឹកនៃកិច្ចដំណើរការសវនាការ", ថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៣, ទំព័រ ៩:៩ ដល់ ២០, ៦៨:១៥ ដល់ ១៩ (ភាសាអង់គ្លេស)។

69. មន្ទីរ ស២១ ក៏ជាមន្ទីរសន្តិសុខតែមួយគត់ដែលត្រូវបានអះអាងថា បានរាយការណ៍ដោយផ្ទាល់ទៅមជ្ឈិមបក្ស។ មន្ទីរសន្តិសុខ និងសហករណ៍ស្ទើរតែទាំងអស់នៅប្រទេសកម្ពុជាត្រូវបានអះអាងថា បានដំណើរការ និង/ឬ បង្កើតឡើងដោយមន្ត្រីនៅមូលដ្ឋាន[146]។ ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០១ បានពណ៌នា មន្ទីរ ស២១ ថា "មានលក្ខណៈពិសេស" ដោយសារវាផ្តោតទៅលើពួកកម្មាភិបាល ប.ក.ក និង ទំនាក់ទំនងរបស់វាជាមួយមជ្ឈិម[147]។ ហេតុនេះ ក្នុងន័យនេះ វាក៏មិនតំណាងឲ្យដីកាដំណោះស្រាយដែរ។

70. វាពុំមែនជា "ប្រយោជន៍នៃយុត្តិធម៌" ទេ ដែលត្រូវបញ្ចូលមន្ទីរ ស២១ ដោយសារតែវាត្រូវបានអះអាងថាជា "ទីតាំងឧក្រិដ្ឋកម្មដែលនៅជិតស្និទ្ធនឹងជនជាប់ចោទជាងគេ"[148]។ ប្រយោជន៍នៃយុត្តិធម៌ពុំដូចប្រយោជន៍នៃការចោទប្រកាន់ដើម្បីធានាឲ្យបានការផ្តន្ទាទោសនោះទេ។ ការបញ្ចូលមន្ទីរ ស២១ ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ ដោយសារវាត្រូវបានចោទប្រកាន់ថាមានទំនាក់ទំនងមិនធម្មតាជាមួយ នួន ជា នឹងបង្កើតឲ្យមានជម្រើសយ៉ាងទូលាយដើម្បីបង្វែរកំណត់ហេតុក្នុងសំណុំរឿង ០០២ ដើម្បីសង្កត់ធ្ងន់បន្ថែមទៀតទៅលើតួនាទីរបស់មេដឹកនាំបក្ស និង ធ្វើឲ្យស្រពិចស្រពិលនូវតួនាទីរបស់ប្រជាជនកម្ពុជាសាម័ញ្ញ និងកម្មាភិបាល ប.ក.ក រាប់ម៉ឺននាក់ទៀត។ នោះនឹងក្លាយជាបរាជ័យដល់ការខិតខំប្រឹងប្រែងរបស់តុលាការដើម្បី "ស្វែងរកការពិត" និងបង្វែររឿងរ៉ាវប្រវត្តិសាស្ត្រមិនខាន។

71. ប្រសិនបើសហព្រះរាជអាជ្ញាចង់កាត់ទោស នួន ជា ពីបទឧក្រិដ្ឋមួយចំនួនតូច ដែលពួកគេជឿថាគាត់ពិតជានៅជិតជាងគេនោះ ពួកគេប្រហែលជាបង្រួញវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ខ្លួនមិនខាន។ សេចក្តីសម្រេចនោះនឹងមានសារៈសំខាន់របស់វាផ្ទាល់ ថាជាការដឹងពីការទទួល

[146] ដីកាដំណោះស្រាយ, កថាខណ្ឌ ៤៧៧, ៤៩០, ៥១៩, ៥៣៧, ៥៥៧, ៦៣០ ដល់ ៦៣១, ៦៤៩, ៦៧០ ដល់ ៦៧១។

[147] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស, ឯកសារលេខ **D99**, "ដីកាដំណោះស្រាយ", ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០០៨, កថាខណ្ឌ ២០។

[148] បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៤៧។

ខុសត្រូវទូលំទូលាយដែលមានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងតួនាទីដ៏រឹតត្បិតរបស់មជ្ឈិមបក្ស។ ផ្ទុយទៅវិញ ពួកគេបែរជាចោទប្រកាន់ នួន ជា ពីការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលមានទ្រង់ទ្រាយធំនៅគ្រប់ជាន់ថ្នាក់នៃរបបនេះ និងនៅគ្រប់ខេត្តក្នុងប្រទេសកម្ពុជាទៅវិញ។ ពួកគេបានផ្តួចផ្តើមឱ្យមានការស៊ើបអង្កេតដែលមានលក្ខណៈជាការឃោសនាខ្លាំងរយៈពេល ៣ ឆ្នាំ ដែលបានជាដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានបញ្ហាតាមផ្លូវតុលាការ ដែលបញ្ជាក់ពីការចោទប្រកាន់ទាំងនោះ។ នាពេលនេះដោយពុំបានវិនិច្ឆ័យទៅលើបទចោទទាំងនោះ ពួកគេមិនអាចត្រឡប់ការចោទប្រកាន់មួយដែលពួកគេជឿថាមានទំនាក់ទំនងបំផុតជាមួយ នួន ជា និងបានកំណត់ថា វាមាន "ភាពជាតំណាង" នៃការទទួលខុសត្រូវរបស់គាត់ចំពោះវិសាលភាពទាំងមូលនៃដីកាដំណោះស្រាយទៅវិញ។

<u>ii – សវនាការពីមុនលើមន្ទីរ ស២១</u>

72. អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ទម្ងន់យ៉ាងសមរម្យដល់ការវិនិច្ឆ័យរបស់ខ្លួនពីមុនចំពោះបទចោទនានាដែលពាក់ព័ន្ធនឹងមន្ទីរ ស២១ ក្នុងសំណុំរឿង ០០១ ថាជាកត្តាពាក់ព័ន្ធមួយក្នុងកត្តានានាជាច្រើនដែលខ្លួនបានពិចារណា[149]។ សវនាការមួយលើការចោទប្រកាន់នានាដែលពាក់ព័ន្ធនឹងមន្ទីរ ស២១ ក្នុងសំណុំរឿង ០០២ នឹងត្រួតគ្នាជាមួយនឹងសវនាការក្នុងសំណុំរឿង ០០១ ទាក់ទិននឹងសេចក្តីសន្និដ្ឋានលើអង្គហេតុ ទាំងចំពោះភស្តុតាងពាក់ព័ន្ធនឹងមូលដ្ឋានបទឧក្រិដ្ឋ និង តួនាទីនិងសំណងដល់ជនរងគ្រោះ។ ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១២៨ នាក់ដែលត្រូវបានទទួលស្គាល់ពាក់ព័ន្ធនឹងមន្ទីរ ស២១ ក្នុងសំណុំរឿង ០០២ មានចំនួន ៤៦ នាក់ត្រូវបានទទួលស្គាល់រួចមកហើយជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០១។ វាជាប្រយោជន៍នៃយុត្តិធម៌ សម្រាប់ឱ្យអង្គជំនុំជម្រះសាលាដំបូងផ្តល់សិទ្ធិដល់សុភវិនិច្ឆ័យនៃការទាមទារសំណង និង ការចោទប្រកាន់លើអង្គហេតុដែលមិនទាន់បានដោះស្រាយសំខាន់ជាងអ្វីដែលបានដោះស្រាយរួចមកហើយ។ ការណ៍ដែលថា ជនជាប់ចោទក្នុងសំណុំរឿង ០០២ ត្រូវបានចោទប្រកាន់ពីការបង្កើតគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ មិនមែនជា

---

[149] សេចក្តីសម្រេចដែលត្រូវបានជំទាស់, កថាខណ្ឌ ១១២។

លក្ខណៈពិសេសចំពោះមន្ទីរ ស២១ ទេ ហើយក៏មិនអាចផ្តល់យុត្តិកម្មដើម្បីយកករណីនេះមកជំនុំជម្រះជាថ្មីទៀតដែរ[150]។

73. ជាងនេះទៀត ការជំនុំជម្រះ ឌុច មិនមែន "សំណុំរឿងផ្សេងទៀតប្រឆាំងនឹងជនជាប់ចោទផ្សេងៗទៀត" ទេ[151]៖ វាជារឿងក្តីដូចគ្នា ដែលត្រូវបានបំបែកក្នុងពេលស៊ើបអង្កេត ដើម្បីអនុញ្ញាតឲ្យ ស.ច.ស អាចផ្តោតទៅលើទីតាំងឧក្រិដ្ឋកម្មតែមួយបាន។ វាផ្ទុយពីប្រយោជន៍នៃយុត្តិធម៌ ដែលត្រូវបើកសវនាការពីរបន្តបន្ទាប់គ្នាលើទីតាំងឧក្រិដ្ឋកម្មតែមួយ ដោយមិនបានវិនិច្ឆ័យទៅលើភាពភាគច្រើនលើសលប់នៃការចោទប្រកាន់ដែលដំបូងឡើយត្រូវបានបង្កើតឡើងប្រឆាំងនឹងជនសង្ស័យ (នាពេលនោះ)។

iii – ការវិនិច្ឆ័យដល់មន្ទីរ ស២១ នឹងនាំឲ្យមានភាពស្មុគស្មាញ

74. ការចោទប្រកាន់ពាក់ព័ន្ធនឹងមន្ទីរ ស២១ មានភាពស្មុគស្មាញ និង ត្រូវបានមេធាវីការពារក្តីជំទាស់។ ហេតុនេះ មេធាវីការពារក្តីមិនបានយល់ស្របជាមួយសហព្រះរាជអាជ្ញាថា ការចោទប្រកាន់ទាំងនោះអាចត្រូវបានយកមកវិនិច្ឆ័យក្នុងរយៈពេល ១៥ ថ្ងៃ ដោយតំណាងឲ្យសាក្សីជាក់លាក់ចំនួន ៥ ក្នុងរយៈពេល ១១ ថ្ងៃ និង ៤ ថ្ងៃទៀតត្រូវផ្តល់ឲ្យសាក្សីផ្សេងៗទៀតដែលមេធាវីការពារក្តីបានស្នើសុំ ឬ ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ[152]។

75. ការផ្តល់សក្ខីកម្មបន្តផ្ទាល់ពាក់ព័ន្ធនឹងមន្ទីរ ស២១ តម្រូវឲ្យធ្វើបាន លុះត្រាតែយ៉ាងហោចណាស់ក៏មានសំអាងហេតុចំនួន ៤ ដែរគឺ៖ ដើម្បីដេញដោលនឹងភាពជឿជាក់បាននៃសក្ខីកម្មរបស់ ឌុច, ដើម្បីបង្ហាញពីតួនាទីជាបន្តរបស់ សុន សេន នៅមន្ទីរ ស២១ ក្រោយថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧, ដើម្បីបង្ហាញថា អ្នកទោសជាជនជាតិវៀតណាមដែលបានឃុំឃាំងនៅមន្ទីរ ស២១ ពុំមែនជាគោលដៅនៃការ

---

150 បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៤៩។

151 បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៤៩។

152 បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៥៣។

ប្រព្រឹត្តបែបរើសអើងទេ និង ដើម្បីបង្ហាញថា អ្នកជាប់ឃុំឃាំងនៅមន្ទីរ ស២១ គឺជាគោលដៅយោធាស្របច្បាប់។ ដូចដែលមេធាវីការពារក្តីបានលើកឡើងរួចមកហើយនៅឯសវនាការរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីគឺថា មេធាវីការពារក្តីនឹងធ្វើសេចក្តីសន្និដ្ឋានលើភស្តុតាងចុងក្រោយពាក់ព័ន្ធនឹងមន្ទីរ ស២១ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ប្រសិនបើ និង នៅពេលដែល មន្ទីរ ស២១ ត្រូវបានបញ្ចូលទៅក្នុងវិសាលភាពនៃសវនាការនោះ[153]។

*ភាពជឿជាក់បានរបស់ ឌុច*

76. កន្លងមក សក្ខីកម្មរបស់ ឌុច គឺជាភស្តុតាងដាក់បន្ទុកខ្លាំងជាងគេនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយសារតែតួនាទីរបស់ នួន ជា នៅមន្ទីរ ស២១។ ឌុច បានអះអាងថា នួន ជា បានគ្រប់គ្រងដោយផ្ទាល់ទៅលើមន្ទីរ ស២១ ពី សុន សេន ចាប់ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧ ហើយបានកាន់តំណែងនោះរហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[154]។ ទោះជាយ៉ាងណាក្តី ភស្តុតាងជាឯកសារបង្ហាញពីតួនាទីរបស់ សុន សេន ដែលបន្តមាននៅមន្ទីរ ស២១ ក្រោយកាលបរិច្ឆេទនោះ[155] ដូចដែលសក្ខីកម្មរបស់អតីតបុគ្គលិកនៅមន្ទីរ ស២១ បានបង្ហាញដែរ[156]។ ចម្លើយពីមុនរបស់ ឌុច ក៏ផ្ទុយពីសក្ខីកម្មរបស់

---

[153] ចម្លើយសាក្សីក្នុងឯកសារនេះជា*ការបន្ថែម*ទៅលើសាក្សីដែលសហព្រះរាជអាជ្ញាបានស្នើសុំ ដែលមេធាវីការពារក្តីបានយល់ព្រមក៏មានសារៈសំខាន់ដល់ការជំនុំជម្រះទៅលើការចោទប្រកាន់នានាដែលពាក់ព័ន្ធនឹងមន្ទីរ ស២១។

[154] ឯកសារលេខ **E1/58.1**, "ប្រតិចារឹកនៃកិច្ចដំណើរការសវនាការ", ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២, ទំព័រ ៧២:៤ ដល់ ៨ (ភាសាអង់គ្លេស)។

[155] ឯកសារលេខ **E3/83**, កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការសួរយកចម្លើយ កាំង ហ្គេចអ៊ាវ, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០០៩, ទំព័រ ៤ (ភាសាអង់គ្លេស) (ដោយពិភាក្សាអំពីឯកសារមួយដែលពាក់ព័ន្ធនឹងបញ្ហានេះ); ឯកសារលេខ **E3/394**, កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការសួរយកចម្លើយ កាំង ហ្គេចអ៊ាវ, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៩, ទំព័រ ៤ (ភាសាអង់គ្លេស) (ស្រដៀងគ្នា)។

[156] *សូមមើល* កថាខណ្ឌ ៧៩, *ខាងក្រោម*។

គាត់នៅក្នុងតុលាការដែរ[157]។ ហេតុនេះ សំណួរពាក់ព័ន្ធនឹងតួនាទីរបស់ នួន ជា នៅមន្ទីរ ស២១ នាំឲ្យមានការជំទាស់ និង បញ្ហាពាក់ព័ន្ធនឹងភាពជឿជាក់បានរបស់ ឌុច។

77. មេធាវីការពារក្តីអាចជំទាស់នឹងភាពជឿជាក់បានរបស់ ឌុច តែតាមរយៈការស្តាប់សក្ខីកម្មបន្តផ្ទាល់ពីអតីតបុគ្គលិកនៅមន្ទីរ ស២១ ប៉ុណ្ណោះ។ ទោះបី ឌុច បានផ្តល់សក្ខីកម្មថា គាត់ពុំមានតួនាទីពិតប្រាកដក្នុងការសួរចម្លើយនៅមន្ទីរ ស២១ និង ពុំមានតួនាទីក្នុងការធ្វើទារុណកម្មទាល់តែសោះក៏ដោយ[158] តែអតីតអ្នកយាម និងអ្នកសួរចម្លើយនៅមន្ទីរ ស២១ ជាច្រើននាក់បានលើកឡើងថា ការពិតគឺផ្ទុយទៅវិញទេ[159]។ មេធាវីការពារក្តីព្យាយាមសួរតទល់ជាមួយ ឌុច ពាក់ព័ន្ធនឹងចម្លើយទាំងនោះនៅពេលសវនាការ តែវិធានមួយដែលពិបាកយល់បានរារាំងមិនឲ្យសួរតទល់នឹងជាមួយសាក្សី ដោយប្រើចម្លើយរបស់សាក្សីម្នាក់ទៀតក្នុងពេលសាកសួរដេញដោល[160]។ ហេតុនេះ ការផ្តល់សក្ខីកម្មបន្តផ្ទាល់ដោយអតីតបុគ្គលិកនៅមន្ទីរ ស២១ គឺជាវិធីតែមួយគត់ដើម្បីតតាំងនឹងសក្ខីកម្មបន្តផ្ទាល់របស់ ឌុច ពាក់ព័ន្ធនឹងតួនាទីរបស់គាត់នៅមន្ទីរ ស២១។

---

157 ឯកសារលេខ **E3/449**, កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការសួរយកចម្លើយ កាំង ហ្គេចអ៊ាវ, ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៨, ទំព័រ ៧ (ភាសាអង់គ្លេស) (ការបន្តចូលរួមរបស់ សុន សេន នៅចុងឆ្នាំ ១៩៧៧)។

158 ឯកសារលេខ **E1/58.1**, "ប្រតិចារឹកនៃកិច្ចដំណើរការសវនាការ", ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១២, ទំព័រ ៧៨:២០ ដល់ ៧៩:៥, ៨៥:២០ ដល់ ៨៦:៦, ៨៧:១៨ ដល់ ៨៨:៣ (ភាសាអង់គ្លេស); ឯកសារលេខ **E1/59.1**, "ប្រតិចារឹកនៃកិច្ចដំណើរការសវនាការ", ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១២, ទំព័រ ៣៨:១៨ ដល់ ៣៩:១ (ភាសាអង់គ្លេស)។

159 ឯកសារលេខ **D108/6/3**, កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ សោម ម៉េត ថ្ងៃទី ២៨, ខែ វិច្ឆិកា ឆ្នាំ ២០០៧, ទំព័រ ៥ (ភាសាអង់គ្លេស); ឯកសារលេខ **E3/68**, កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ ញ៉ែម អេន, ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០០៧; ឯកសារលេខ **D108/3/13**, កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ ឡាច មាន, ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៧, ទំព័រ ១០ (ភាសាអង់គ្លេស) (ឌុច បានចូលបន្ទប់សួរចម្លើយ "ជាញឹកញយ"); ឯកសារលេខ **D108/3/14**, កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ ម៉ម ណៃ, ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៧, ទំព័រ ១២ (ភាសាអង់គ្លេស)។

160 ឯកសារលេខ **E1/59.1**, "ប្រតិចារឹកនៃកិច្ចដំណើរការសវនាការ", ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១២, ទំព័រ ៣៧:១ ដល់ ៤៤:១៣ (ភាសាអង់គ្លេស)។

78. មានទំនាក់ទំនងមួយដោយផ្ទាល់រវាងភាពជឿជាក់បាននៃសក្ខីកម្មរបស់ ឌុច ពាក់ព័ន្ធនឹងតួនាទីរបស់គាត់នៅក្នុងការធ្វើទារុណកម្ម និង សក្ខីកម្មរបស់គាត់ពាក់ព័ន្ធនឹងតួនាទីរបស់ នួន ជា ក្នុងនាមថ្នាក់លើរបស់គាត់គឺថា៖ សក្ខីកម្មទាំងពីរនេះបង្ហាញពីឆន្ទៈរបស់ ឌុច ក្នុងការគេចចេញពីការទទួលខុសត្រូវរបស់ខ្លួនចំពោះបទឧក្រិដ្ឋនានាដែលបានប្រព្រឹត្តនៅមន្ទីរ ស២១ ទៅឲ្យអ្នកផ្សេងទៀត។ អង្គជំនុំជម្រះនេះបានលើកឡើងច្បាស់លាស់ហើយពីការព្រួយបារម្ភនោះគឺថា៖

> កាំង ហ្គេចអ៊ាវ បានខកខានក្នុងការផ្តល់នូវទិដ្ឋភាពពេញលេញនៃការយល់ដឹងអំពីអង្គហេតុរបស់ខ្លួននៅក្នុងរឿងក្តីនេះ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បី*កាត់បន្ថយជាអតិបរមានូវតួនាទីរបស់ខ្លួននៅក្នុងឧក្រិដ្ឋកម្មទាំងឡាយ*។ កាំង ហ្គេចអ៊ាវ បានគេចវេសដោយប្រុងប្រយ័ត្ន ក្នុងការឆ្លើយតបដោយពេញលេញនៅពេលប្រឈមនឹងការចោទប្រកាន់នានា ដែលទាក់ទងនឹងការចូលរួមដោយផ្ទាល់របស់ខ្លួនទៅក្នុងឧក្រិដ្ឋកម្មទាំងឡាយ *ដោយទម្លាក់កំហុសការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងនោះទៅលើអ្នកដទៃទៅវិញ* ហើយបានធ្វើសេចក្តីថ្លែងការណ៍ដែលមិនស៊ីសង្វាក់ជាមួយនឹងភស្តុតាងដែលមាន[161] (គូសបញ្ជាក់បន្ថែម)។

មេធាវីការពារក្តីមានសិទ្ធិលើកឡើងនូវសំណួរទាំងនេះនៅពេលសវនាការ ដើម្បីធ្វើឲ្យអង្គជំនុំជម្រះសាលាដំបូងជឿថា អង្គជំនុំជម្រះគួរតែរិះគន់ដូចគ្នាដែលចំពោះសក្ខីកម្មរបស់ ឌុច។

*<u>តួនាទីរបស់ សុន សេន</u>*

79. ដូចបានកត់សម្គាល់រួចមកហើយគឺថា ឌុច បានផ្តល់សក្ខីកម្មថា នួន ជា បានជំនួស សុន សេន ជាថ្នាក់លើរបស់គាត់ពាក់ព័ន្ធនឹង មន្ទីរ ២១ បន្ទាប់ពី សុន សេន បានចេញដំណើរទៅភូមិភាគបូព៌ានៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៧។ អតីតបុគ្គលិកមន្ទីរ ស២១ បានផ្តល់សក្ខីកម្មថា សុន សេន នៅបន្តមកមន្ទីរ

161 សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជតក, ឯកសារលេខ **F28**, "សាលដីកា", ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ("សាលដីកាលើរឿងក្តី ឌុច"), កថាខណ្ឌ ៣៦៨។

ស២១ មួយសប្តាហ៍ម្តងជាទៀងទាត់រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[162]។ ក្នុងការផ្តល់សក្ខីកម្មក្នុងតុលាការពាក់ព័ន្ធនឹងបញ្ហានោះនឹងផ្តល់នូវភស្តុតាងផ្ទុយពី ឌុច ដោយផ្ទាល់ ហើយវានឹងក្លាយជាការដោះបន្ទុកវិញ ពាក់ព័ន្ធនឹងតួនាទីរបស់ នួន ជា។

*ការកំណត់ជាគោលដៅនូវជនជាតិវៀតណាម*

80. ការផ្តល់សក្ខីកម្មបន្តផ្ទាល់របស់អ្នកយាម និង អ្នកសួរចម្លើយនៅមន្ទីរ ស២១ គឺត្រូវឲ្យមាន ដើម្បីបង្ហាញថា ការចោទប្រកាន់ដែលថា "ប្រជាជនវៀតណាមត្រូវបានធ្វើទុក្ខបុកម្នេញ ពីព្រោះថា ប.ក.ក ចាត់ទុកជនជាតិវៀតណាមថាជាពូជសាសន៍ដទៃ ខុសពីពូជសាសន៍ខ្មែរ ដោយផ្អែកលើសែស្រឡាយខាងម្តាយ"[163] គឺជាកំហុសឆ្គង។ សហព្រះរាជអាជ្ញាបានដកស្រង់នូវចោទប្រកាន់ជាក់លាក់នេះធ្វើជាការចូលរួមចំណែកមួយរបស់មន្ទីរ ស២១ ចំពោះភាពជាតំណាងនៃសវនាការលើសំណុំរឿង 00២/0១ ដែលពួកគេបានស្នើសុំដល់អង្គជំនុំជម្រះនេះ[164]។

81. មេធាវីការពារក្តីសូមជំទាស់ថា ជនជាតិវៀតណាមពុំមែនជាគោលដៅបែបនោះទេ។ វៀតណាមជាសត្រូវផ្អែកយោធាស្របច្បាប់ដែលចង់ត្រួតត្រាទឹកដីកម្ពុជា បានប៉ុនប៉ងធ្វើបែបនេះម្តងហើយម្តងទៀតចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ហើយជាចុងក្រោយបានទទួលជោគជ័យនៅថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។ បន្ទាប់មកកងទ័ពវៀតណាមបានកាន់កាប់ទឹកដីកម្ពុជាអស់រយៈពេល ១០ ឆ្នាំ។ ចម្លើយនានាពីបុគ្គលិកនៅមន្ទីរ ស២១ បង្ហាញថា អ្នកជាប់ឃុំឃាំងវៀតណាមត្រូវបានសួរចម្លើយជាចម្បងអំពី

---

162 ឯកសារលេខ E3/68, កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ ប៉ៀម អេន, ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២00៧, ទំព័រ ១៣ ដល់ ១៤ (ភាសាអង់គ្លេស) (សុន សេន មកជាទៀងទាត់រហូតដល់ពួកវៀតណាមមកដល់); ឯកសារលេខ D108/3/13, កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ ឡាច មាន, ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២00៧, ទំព័រ ១១ (ភាសាអង់គ្លេស) (ទោះបីគាត់ជឿថា គាត់បានមកដល់ទួលស្លែងនៅឆ្នាំ ១៩៧៧ ក៏ដោយ ក៏គាត់បានឃើញ សុន សេន នៅទួលស្លែង "ជាញឹកញយ រៀងរាល់មួយខែ ឬពីរខែ")។

163 ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤២២។

164 បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ ៤0។

សភាពការណ៍យោធានៅតាមព្រំដែន ជាជាងពីបណ្ដាញខ្សែក្បត់[165]។ សក្ខីកម្មកម្រិតនោះនឹងបង្ហាញថា ជនជាតិវៀតណាមមិនត្រូវបានធ្វើទុក្ខបុកម្នេញនៅមន្ទីរ ស២១ ដោយសារមូលហេតុជាតិសាសន៍ ឬជាតិពន្ធុទេ តែពួកគេត្រូវបានឃុំឃាំងសម្រាប់គោលបំណងយោធាស្របច្បាប់តែប៉ុណ្ណោះ។

*<u>ការគំរាមកំហែងរបស់ខ្មាំងសត្រូវនៅក្នុងប្រទេសកម្ពុជា</u>*

82. ច្បាប់មនុស្សធម៌អន្តរជាតិបានថែងពីការប្រើអំពើហិង្សាក្រៅប្រព័ន្ធតុលាការ និងសូម្បីតែការធ្វើមនុស្សឃាត ប្រឆាំងនឹងបុគ្គលពាក់ព័ន្ធនឹងការចូលរួមយ៉ាងសកម្មក្នុងការរៀបចំផែនការគំរាមកំហែងធ្ងន់ធ្ងរដល់សន្តិសុខរបស់រដ្ឋ។ នាពេលថ្មីៗនេះរដ្ឋាភិបាលសហរដ្ឋអាមេរិកបានអនុវត្តអំពើមនុស្សឃាតក្រៅប្រព័ន្ធតុលាការដោយបណ្ដាលឲ្យមានការស្លាប់រង្គាលដល់ជនស៊ីវិលជាទ្រង់ទ្រាយធំជាប្រក្រតី និងបន្តបន្ទាប់ ហើយបានផ្ដល់យុត្តិកម្មដល់ទង្វើនោះថាជាទម្លាប់អនុវត្តន៍តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[166]។ ពាក់ព័ន្ធនឹងការគំរាមកំហែងដែលរបបកម្ពុជាប្រជាធិបតេយ្យបានប្រឈមមុខដែលពិតជាលេចចេញជារូបរាងនោះគឺថា ភាពទំនងដែលថាពួកបង្កវិទ្ធង្សនានៅមានក្នុងប្រទេសមុនឆ្នាំ ១៩៧៩

---

[165] ឯកសារលេខ **E3/351**, កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយ ម៉ម ណៃ, ថ្ងៃទី ៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧, ទំព័រ ៥, ១៣ ដល់ ១៦ (ភាសាអង់គ្លេស); ឯកសារលេខ **D108/22/2**, កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយ ម៉ម ណៃ, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៨, ទំព័រ ៣ (ភាសាអង់គ្លេស) (ជានិច្ចកាល អ្នកទោសវៀតណាមជាទាហាន); ឯកសារលេខ **D108/3/11**, កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយ នឹម គីមស្រៀង, ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៧, ទំព័រ ៦ ដល់ ៧ (ស្រដៀងគ្នា) (ភាសាអង់គ្លេស); ឯកសារលេខ **IS19.167**, កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សោម ម៉េត, ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៣, ទំព័រ ២៧ (ភាសាអង់គ្លេស); ឯកសារលេខ **E3/352**, កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយ ប៉េស ម៉ាត, ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៨, ទំព័រ ៤ (ភាសាអង់គ្លេស) (បានឃើញទាហានវៀតណាមក្នុងឯកសណ្ឋានជាយោធា ប្រជាជនកម្ពុជា និងវៀតណាមត្រូវបានគេប្រព្រឹត្តដូចគ្នា)។

[166] "ភាពស្របច្បាប់នៃប្រតិបត្តិការណ៍សម្លាប់មនុស្សត្រូវបានធ្វើឡើងដោយផ្ទាល់ប្រឆាំងនឹងពលរដ្ឋនៃ ស.រ.អា រូបណាដែលជាមេដឹកនាំប្រតិបត្តិការណ៍ជាន់ខ្ពស់របស់ក្រុម Al-Qa'ida ឬកងកម្លាំងជាសម្ព័ន្ធមិត្រ" (សៀវភៅស របស់ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក, ឆ្នាំ ២០១២)។

គឺជាការពិត។ ភស្តុតាងបង្ហាញថា គិញរបស់សេអ៊ីអាបានដំណើរការនៅក្នុងប្រទេសកម្ពុជាមុនឆ្នាំ ១៩៧៥ ហើយថា រដ្ឋាភិបាលសហរដ្ឋអាមេរិកគឺជាគូបដិបក្ខដ៏មោះមុតរបស់របប ប៉ុល ពត[167]។

83. ដោយសារ ឌុច ជ្រើសរើសមិនតវ៉ាចំពោះការចោទប្រកាន់ដែលថា បទល្មើសព្រហ្មទណ្ឌត្រូវបានប្រព្រឹត្តនៅមន្ទីរ ស២១ នោះ ពុំមានការពិចារណាស៊ីជម្រៅណាមួយថាតើភាពចាំបាច់ផ្នែកយោធាបានផ្តល់យុត្តិកម្មដល់អំពើទាំងនោះឡើយ។ ការផ្តល់សក្ខីកម្មរបស់អតីតអ្នកយាម និងអ្នកសួរចម្លើយនៅមន្ទីរ ស២១ ជាការចាំបាច់ ដើម្បីបង្ហាញពីការបានដឹងរបស់ពួកគេចំពោះសិទ្ធិអាជ្ញាបញ្ញាទាំងនេះ។

## IV. សេចក្តីសន្និដ្ឋាន និង សំណូមពរ

84. មេធាវីការពារក្តីសូមស្នើសុំដោយគោរពដល់អង្គជំនុំជម្រះតុលាការកំពូលមេត្តា៖

ក. **ទទួលយក**បណ្តឹងសាទុក្ខ និង សារណាតបនេះ។

ខ. **ទុកជាមោឃៈ** នូវសេចក្តីសម្រេចដែលត្រូវបានជំទាស់ ដោយសារវាប៉ះពាល់ដល់ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនានានាពេលអនាគត។ ឬ ជាជម្រើសម្យ៉ាងទៀត

គ. **ទុកជាមោឃៈ** នូវសេចក្តីសម្រេចដែលត្រូវបានជំទាស់ និង **បង្គាប់ឲ្យ** អង្គជំនុំជម្រះសាលាដំបូងបង្កើតនូវភាពជាតំណាងសមហេតុផលដល់ ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២ ឲ្យបានពេញលេញ ដែលបញ្ចូលបទចោទនៃអំពើប្រល័យពូជសាសន៍ និងបទចោទនានាដែលពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តនៅតាមសហករណ៍ និងការដ្ឋាន។ និង

ឃ. **បដិសេធចោល** នូវបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីទាំងស្រុង។

---

167 ឯកសារលេខ **E3/9**, "ប៉ុល ពត៖ ប្រវត្តិនៃសុបិន្តអាក្រក់មួយ", ទំព័រ ២៨៧ (ភាសាអង់គ្លេស) (ភ្នាក់ងារ CIA ឈ្មោះ Frank Snepp បានគូសបញ្ជាក់ថា ការជម្លៀសប្រជាជនចេញពីទីក្រុងបានបំផ្លាញបណ្តាញ CIA នៅប្រទេសកម្ពុជា)។

**សហមេធាវីការពារក្ដី នួន ជា**

សុន អារុណ

Victor KOPPE